**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**សារណាបញ្ចប់ការសិក្សា**

# ប្រព័ន្ធទ្រព្យសម្បត្តិរួម

# របស់ប្តីប្រពន្ធ

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **សាន គឹមណាន**

សាស្ត្រាចារ្យណែនាំ

លោក **ហេង មូរ៉ា**

ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ឆ្នាំចូលសិក្សា ២០១៧

ជំនាន់ទី ២១

ឆ្នាំសរសេរបាយការណ៍២០២១

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំសូមសម្តែងការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកឪពុក អ្នកម្តាយ ដែលបាន ផ្តល់ជីវិតចិញ្ចឹមបីបាច់ថែរក្សា និងបានផ្តល់នូវក្តីស្រលាញ់ មេត្តា ករុណា អប់រំទូន្មានកូនឲ្យមាន សេចក្តីព្យាយាមក្នុងជីវិត។ ព្រមទាំងសូមអរគុណអ្នកមានគុណទាំងពីរ ដែលបានធ្វើពលិកម្មគ្រប់យ៉ាង សម្រាប់ការសិក្សារបស់កូនទទួលបាននូវចំណេះដឹងដ៏ថ្លៃថ្លា ។

នាងខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកសាស្ត្រាចារ្យ **ហេង ប៉ូរ៉ា** ជាសាស្ត្រាចារ្យណែនាំដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃ លះបង់អស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីជួយ ណែនាំផ្តល់នូវដំបូន្មានកែសម្រួល និងតម្រង់ទិសយើងខ្ញុំរហូតដល់សារណានេះទទួលបានភាព ជោគជ័យគួរជាទីមោទនៈ។

ជាកិច្ចបញ្ចប់នាងខ្ញុំជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានជួបតែសំណាងល្អ ទទួលបាននូវភាពជោគជ័យក្នុងជីវិត និងមានភាពសុខដុមរមនាក្នុងជីវិតជាសហព័ទ្ធរបស់ខ្លួន និងជួបប្រទះនូវពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ដោយអាស្រ័យទៅលើ តម្រូវការដ៏ចំបាច់របស់មនុស្សលោក និងបរិបទនៃសង្គមនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស ការប្រាស្រ័យទាក់ទងគ្នាគឺជាកត្តាចាំបាច់ដែលមិនអាចជៀសផុតអំពីទំនាក់ទំនងនេះឡើយក្នុងសង្គមសព្វថ្ងៃ។ នៅក្នុងការប្រាស្រ័យទាក់ទងគ្នានេះផងដែរ មនុស្សរមែងតែងតែប្រព្រឹត្តនូវកំហុសខុសឆ្គងមិនថានៅក្នុងគ្រួសារ នៅសាលារៀន ទីសាធារណៈ ឬកន្លែងផ្សេងៗទៀតដែលជាមូលហេតុចម្បងធ្វើឲ្យមានភាពមិនយល់ស្រប និងជម្លោះ រវាងបគ្គល និងបុគ្គលកើតឡើង។ ក្រៅពីការចរចារ សម្រុះសម្រួលគ្នាដោយប្រើតាមសន្តិវិធី ក្នុងការដោះស្រាយជម្លោះឬវិវាទ ច្បាប់ផ្សេងៗផ្សេងៗទៀតក៏ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ក្នុងការដោះស្រាយដ៏សមស្រប និងប្រកបទៅដោយប្រសិទ្ធភាព សម្រាប់បំពេញតម្រូវការរបស់ប្រជាពលរដ្ឋ។

ដូចនេះដើម្បីចូលរួមចំណែក្នុងការកាត់បន្ថយ និងរកដំណោះស្រាយសម្រាប់វិវាទនេះ នាងខ្ញុំជានិស្សិតនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានទទួលភារកិច្ច ក្នុងការសរសេរនូវសារណាបញ្ចប់ឆ្នាំសិក្សា ២០២០ - ២០២១ ដោយជ្រើសរើស **ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ** ជាប្រធានបទសម្រាប់ស្រាវជ្រាវ និងសិក្សាស្វែងយល់បន្ថែមដើម្បីបង្កើនភាពយល់ដឹងទាក់ទងទៅនឹងកាតព្វកិច្ចរបស់សហព័ទ្ធក្នុងការគ្រប់គ្រងប្រព័ន្ធទ្រព្យសម្បត្តិ។

ដូច្នេះនាងខ្ញុំជឿជាក់ថាកម្រងសារណារបស់នាងខ្ញុំនឹងចូលរួមចំណែកមួយផ្នែកក្នុងការ ផ្តល់នូវចំណេះដឹងទៅលើប្រធានបទខាងលើនេះជូនប្រជាពលរដ្ឋដើម្បីយកទៅប្រើប្រាស់ក្នុងសង្គម និងក្នុង គ្រួសារក៏ដូចជាចែករំលែកការយល់ដឹងទៅដល់សិស្សានុសិស្សជំនាន់ក្រោយ។ ស្របពេលជាមួយគ្នានេះដែរ នាងខ្ញុំក៏សូមអភ័យទោសនូវរាល់កំហុសខុសឆ្គងទៅលើផ្នែកមួយណាដែលនាងខ្ញុំបានធ្វើឡើង ដោយអចេតនា។ នាងខ្ញុំនឹងរង់ចាំនូវរាល់ការរិះគន់ដើម្បីស្ថាបនា និងមតិផ្សេងៗពីលោក លោកស្រី និងប្រិយមិត្តជាទីគោរពដែលបានចំណាយពេលវេលាដ៏មានតម្លៃមកអាននូវសៀវភៅមួយនេះ។

# មាតិកា


**សេចក្តីផ្តើម** ........ ១

**ជំពូកទី១ ដើមកំណើតនៃប្រព័ន្ធទ្រព្យសម្បត្តិ** ........ ៣

១.១ ប្រភពនៃប្រព័ន្ធទ្រព្យសម្បត្តិ ........ ៣

១.២ និយមន័យប្រព័ន្ធទ្រព្យសម្បត្តិ ........ ៤

១.៣ ប្រភេទប្រព័ន្ធទ្រព្យសម្បត្តិ ........ ៤

១.៣.១ ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា ........ ៥

១.៣.២ ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់កំណត់ ........ ៦

១.៤ ប្រភេទនៃទ្រព្យសម្បត្តិសម្បត្តិរបស់សហព័ទ្ធ ........ ៧

១.៤.១ ទ្រព្យសម្បត្តិដោយឡែក ........ ៧

១.៤.២ ទ្រព្យសម្បត្តិរួម ........ ១១

**ជំពូកទី២ ការកែតម្រូវ ផ្លាស់ប្តូរ និងការបញ្ចប់ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធ** ........ ១៣

២.១ ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា ........ ១៣

២.១.១ ការផ្លាស់ប្តូរកិច្ចសន្យា ........ ១៤

២.១.២ ការកែតម្រូវកិច្ចសន្យា ........ ១៤

២.២ ការបញ្ចប់ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់កំណត់ ........ ១៦

**ជំពូកទី៣ ការបែងចែកទ្រព្យសម្បត្តិ និងភាតព្វកិច្ចរបស់សហព័ទ្ធ** ........ ២១

៣.១ ការបែងចែកទ្រព្យសម្បត្តិតាមកិច្ចសន្យា ........ ២១

៣.២ ការបែងចែកទ្រព្យសម្បត្តិតាមច្បាប់កំណត់ ........ ២១

៣.២.១ ការព្រមព្រៀងពីសហព័ទ្ធ ........ ២២

៣.២.២ សេចក្តីសម្រេចរបស់តុលាការ ........ ២២

**សេចក្តីសន្និដ្ឋាន** ........ ២៧

**អនុសាសន៍** ........ ២៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ជាការពិតណាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ការរៀបអាពាហ៍ពិពាហ៍គឺជាទំនៀមទំលាប់ដែលមានមកតាំងពីបុរាណកាលមកម្លេះ។ ដូនតា និងបុព្វបុរសខ្មែរបានបន្សល់ទុកនូវទំនៀមទំលាប់ដ៏ប្រពៃមួយនេះសម្រាប់កូនចៅជំនាន់ក្រោយដើម្បីស្នងត្រកូល បន្តវេនបង្កើតគ្រួសារ និងបន្តវង្សត្រកូល របស់ខ្លួនពីមួយជំនាន់ទៅមួយជំនាន់ទៀត។ នៅប្រទេសកម្ពុជាចំណងអាពាហ៍ពិពាហ៍កើតឡើងបាន និងត្រឹមត្រូវតាមច្បាប់កំណត់នៅពេលអាពាហ៍ពិពាហ៍នោះបានចុះសំបុត្រអាពាហ៍ពិពាហ៍ដោយ ក្រុមព្រឹក្សាឃុំសង្កាត់។[1] កូនប្រុសស្រីបានដល់វ័យជំទង់ និងដល់ពេលដែល ពួកគេសម្រេចចិត្តយកគូរស្រករដើម្បីចាប់ដៃគ្នាជាគូជាស្វាមី និងភរិយារួមសុខ រួមទុក្ខជាមួយគ្នា និងបង្កើតគ្រួសារដ៏មានសុភមង្គលមួយ។

ជាប្រវត្តិសាស្ត្រអាពាហ៍ពិពាហ៍តំណាងឱ្យរចនាសម្ព័នលំដាប់មូលដ្ឋាននៃសង្គមក្នុងន័យសង្គម និងច្បាប់។ ចំណងអាពាហ៍ពិពាហ៍កើតឡើងបានលុះត្រាតែចំណែកដ៏សំខាន់នៃទ្រព្យសម្បត្តិត្រូវបានគ្រប់គ្រងពង្រីក និងឆ្លងកាត់ក្នុងបរិបទដែលទាក់ទងនឹងអាពាហ៍ពិពាហ៍យ៉ាងច្បាស់លាស់។ ការរស់នៅជាមួយគ្នាក្នុងនាមជាស្វាមី និងភរិយា ខុសពីការរស់នៅក្នុងរូបភាពផ្សេងៗទៀត។ ជាការពិតណាស់ ចំណងអាពាហ៍ពិពាហ៍មិនត្រឹមតែស្វាមី និងភរិយាមានឈ្មោះជាប្តីប្រពន្ធស្របច្បាប់ នោះទេ លើសពីនេះទៅទៀតសហព័ទ្ធមានភារកិច្ចក្នុងការរស់នៅ និងការចាត់ចែងទ្រព្យសម្បត្តិ ផងដែរ។ ហេតុនេះហើយទើបច្បាប់ត្រូវបានបង្កើតឡើងដើម្បីអាស្រ័យ និងធ្វើឲមានភាពងាយស្រួល ក្នុងការចាត់ចែងទ្រព្យសម្បត្តិរវាងសហព័ទ្ធជៀសវាងជម្លោះ ដែលអាចកើតមានឡើងក្រោលពេលរៀបអាពាហ៍ពិពាហ៍។

បន្ទាប់ពីការស្រាវជ្រាវ និងសង្កេតមើលអំពីទិដ្ឋភាពទាំងនេះកិច្ចសន្យាអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើងជាទម្រង់យ៉ាងសមស្របក្នុងលក្ខណៈជាសម្ភារៈប្រភពសម្រាប់សហព័ទ្ធ ក្នុងការចាត់ចែងទ្រព្យសម្បត្តិរវាងភាគីទាំងសងខាង។ សំខាន់ជាងនេះទៅទៀតពួកគេមានលទ្ធភាពស្វែងយល់អំពីសំនួរបីយ៉ាងៈ

- តើធនធានអ្វីខ្លះដែលត្រូវបានផ្ទេរក្នុងឱកាសអាពាហ៍ពិពាហ៍?
- តើកូនក្រមុំនិងកូនកំលោះបានឈានដល់កិច្ចព្រមព្រៀងអ្វីខ្លះក្នុងការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិក្នុងអំឡុងពេលអាពាហ៍ពិពាហ៍?
- កាតព្វកិច្ចក្នុងការថែរក្សា ចាត់ចែងទ្រព្យសម្បត្តិរបស់សហព័ទ្ធត្រូវបានអនុវត្តយ៉ាងដូចម្តេច?˝

[1] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៥៥

ដើម្បីឆ្លើយតបទៅនឹងសំណួរខាងលើ ជាមុនដំបូងយើងគួរយល់ដឹងអំពីប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធជាមុនសិន ដោយយោងទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ។ ដូច្នេះ យើងនឹងធ្វើការសិក្សាទាក់ទងទៅនឹងប្រភេទនៃប្រព័ន្ធសហព័ទ្ធ ប្រព័ន្ធនីមួយៗនៃការគ្រប់គ្រង ទ្រព្យសម្បត្តិរបស់សហព័ទ្ធ ឲ្យបានស៊ីជម្រៅទាំងអស់គ្នា។

# ជំពូកទី១ ដើមកំណើតនៃប្រព័ន្ធទ្រព្យសម្បត្តិ

ប្រព័ន្ធទ្រព្យសម្បត្តិមានដើមកំណើតនៅក្នុងយុត្តាធិការច្បាប់ស៊ីវិល ប៉ុន្តែឥឡូវនេះក៏ត្រូវបានរកឃើញនៅក្នុងយុត្តាធិការច្បាប់ទូទៅមួយចំនួនផងដែរ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ប្រទេសកម្ពុជាយើងធ្លាប់បានឆ្លងកាត់សង្គ្រាម និងរបបប្រល័យពូជសាស្ត្រ ដ៏រាំរ៉ៃដែលជាហេតុធ្វើឲ្យប្រព័ន្ធច្បាប់របស់កម្ពុជាត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងដោយសារតែអកុសលហេតុដ៏ឃោរឃៅនេះ។

តាមដែលយើងបានឃើញសង្គ្រាមកើតមានពីវិវាទ ភាពមិនចុះសម្រុងរវាងបុគ្គល និងបុគ្គល។ ភាពមិនចុះសម្រុងគ្នាមិនមែនកើតឡើងក្នុងសង្គ្រាមតែមួយនោះទេ វិវាទគឺជាសកម្មភាពមួយដែលមនុស្សគ្រប់រូបជួបប្រទះក្នុងសង្គម។ ហេតុនេះហើយដើម្បីដោះស្រាយវិវាទនិង ដើម្បីពង្រឹងយន្តការនៃការដោះស្រាយជម្លោះដែលកើតឡើងប្រកបដោយប្រសិទ្ធភាពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗត្រូវបានគេយកមកប្រើប្រាស់។

ជាការពិតណាស់ គ្មានបុគ្គលណាម្នាក់អាចជៀសផុតពីវិវាទបានឡើយ ជាក់ស្តែងនៅក្នុងសង្គមខ្មែរ វិវាទមានគ្រប់ទម្រង់ក្នុងស្ថានភាពខុសៗគ្នា ជាពិសេសបើសិនជានិយាយក្នុងរឿងអាពាហ៍ពិពាហ៍ និងគ្រួសារ បញ្ហា ឬ វិវាទភាគច្រើនរមែងតែងតែមានការជាប់ទាក់ទងអំពីបញ្ហាទ្រព្យសម្បត្តិ។ ជានិច្ចកាលតែងតែកើតមានឡើងនៅក្នុងបាតុភូតសង្គមជាក់ស្តែង គ្រួសារក៏ដោយ ស្វាមីភរិយាក៏ដោយតែងតែមានបញ្ហាជម្លោះទាក់ទងអំពីបញ្ហាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធទើបធ្វើឲ្យ ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធមានការវិវត្តទៅមុខឥតឈប់ឈរ។

## ១.១ ប្រភពនៃប្រព័ន្ធទ្រព្យសម្បត្តិ

ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធនេះគឺ មានតាំងពីមុនការបង្កើតនូវប្រព័ន្ធទ្រព្យសម្បត្តិដែលចែងនៅ ក្នុងក្រមរដ្ឋប្បវេណីទៅទៀត។ យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រភេទទ្រព្យសម្បត្តិមាន២ប្រភេទ គឺទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដាច់ដោយឡែក។ ទ្រព្យសម្បត្តិរួមគឺជាស្ថាប័នដែលមានលក្ខណៈពិសេសចំពោះច្បាប់ស៊ីវិល ប៉ុន្តែប្រភពដើមពិតប្រាកដរបស់វាមិនដែលត្រូវបានកំណត់ឱ្យច្បាស់លាស់ទេ។ ប្រព័ន្ធទ្រព្យសម្បត្តិរួមត្រូវបានគេគិតថាជាទូទៅ បានមកពីទំនៀមទម្លាប់ប្រពៃណីអាឡឺម៉ង់ចាស់ និងច្បាប់ប្រជាប្រិយបានសាយភាយពាសពេញទ្វីប អឺរ៉ុបដោយការធ្វើចំណាកស្រុករបស់បារីនបន្ទាប់ពីការដួលរលំនៃចក្រភពរ៉ូមខាងលិច។[2]

[2] សូមមើលវេបសាយ៖ https://digitalcommons.law.lsu.edu/cgi/viewcontent.cgi?article=3293&context=lalrev

ប្រវត្តិនៃច្បាប់ទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍បង្ហាញពីការរីករាលដាលបន្តិចម្តងៗ នៃប្រព័ន្ធទ្រព្យសម្បត្តិរួម។ នៅទីក្រុងរ៉ូមបុរាណ ប្រពន្ធមានទ្រព្យសម្បត្តិតិចតួចមុនពេលរៀបអាពាហ៍ពិពាហ៍ទ្រព្យសម្បត្តិដែលប្រពន្ធមាននោះនឹងក្លាយជាទ្រព្យសម្បត្តិរបស់ប្តីពួកគេនៅពេលរៀបការ។[3]

## ១.២ និយមន័យប្រព័ន្ធទ្រព្យសម្បត្តិ

មុននឹងឈានទៅដល់ការពន្យល់ពាក្យ "ប្រព័ន្ធទ្រព្យសម្បត្តិ" យើងយោងគួរស្វែងយលថាតើពាក្យ "ទ្រព្យសម្បត្តិ" មានន័យយ៉ាងដូចម្តេច។ ទ្រព្យសម្បត្តិសំដៅទៅលើ មានន័យថា ទ្រព្យគ្រប់ប្រភេទ ទោះជាចលនវត្ថុ ឬជាអចលនវត្ថុ រូបីយ ឬអរូបីយ និងឯកសារគតិយុត្ត ឬលិខិតូបករណ៍ដែលបញ្ជាក់ពីកម្មសិទ្ធិ ឬផលប្រយោជន៍នៅក្នុងទ្រព្យសម្បត្តិនោះ។

ប្រព័ន្ធទ្រព្យសម្បត្តិធ្វើឡើងក្នុងគោលបំណងដើម្បី ការពារសិទ្ធិរបស់ភាគីដែលជាសហព័ទ្ធ និងទប់ស្កាត់ជាមុនមិនឲ្យមាន ការកែប្រែផ្លូវច្បាប់ និងស្ថានភាពជាក់ស្តែង ព្រមទាំងកំណត់ឲ្យបានច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ និងចងភ្ជាប់នូវចំណងកាតព្វកិច្ចប្តីប្រពន្ធ ក្នុងតម្រូវការគ្រួសារ និងបង្ការនូវភាពស្មុគស្មាញក្នុងការធ្វើបំណែងចែកទ្រព្យសម្បត្តិនៅពេលដែល សហព័ទ្ធអាពាហ៍ពាពិពាហ៍ផងដែរ។

## ១.៣ ប្រភេទប្រព័ន្ធទ្រព្យសម្បត្តិ

នៅក្នុងសកលលោកនេះ ច្បាប់ស្តីពីការបែងចែកទ្រព្យសម្បត្តិត្រូវបានបែងចែក និងអនុវត្តខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ។ ក្នុងនាមជាប្តីប្រពន្ធ ការបែងចែកទ្រព្យសម្បត្តិគឺ ជាកត្តាមួយ ដែលភាគីប្តី ឬប្រពន្ធត្រូវបែងចែកឲមានសមាមាត្រភាពរវាងគ្នា និងគ្នាដើម្បីជៀសវាងការមានវិវាទរវាងសហព័ទ្ធ។ ដើម្បីភាពងាយស្រួល និងជៀសវាងក្នុងការដោះចម្ងល់រវាងការបែងចែក និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ ការកំណត់ប្រភេទទ្រព្យសម្បត្តិរបស់សហព័ទ្ធនេះត្រូវបានរៀបរៀងឡើង ដោយយោងទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ប្រព័ន្ធនៃការគ្រប់គ្រង ទ្រព្យសម្បត្តិរបស់ សហព័ទ្ធត្រូវបានបែងចែកចេញជាពីរប្រភេទគឺៈ

- ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមរយៈកិច្ចសន្យា

[3] សូមមើលវេបសាយ៖ https://www.britannica.com/topic/community-property

– ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមរយៈច្បាប់កំណត់។

### ១.៣.១ ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា

ក្រមរដ្ឋប្បវេណីខ្មែរទុកលទ្ធភាពឲ្យប្ដីប្រពន្ធ ធ្វើកិច្ចសន្យា ដើម្បីកំណត់ការបែងចែក និងការចាត់ចែងទ្រព្យសម្បត្តិ ដែលគេហៅថាប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា។ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាសំដៅទៅលើការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ ដោយប្ដីប្រពន្ធទាំងសងខាងបានព្រមព្រៀងបង្កើតកិច្ចសន្យាក្នុងការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិក្នុងរង្វង់គ្រួសាររបស់ខ្លួន។ ការលែងលះគ្នារមែងតែមានមិនថានៅប្រទេសណាឡើយ ប៉ុន្តែបើសិនជាយើងមកសង្កេតមើលមកប្រទេសកម្ពុជាវិញ គូស្វាមីភរិយាភាគច្រើនតែងតែប្រឈមមុខនឹងវិវាទការបែងចែកទ្រព្យសម្បត្តិ នៅពេលដែលពួកគេសម្រេចចែកផ្លូវគ្នាមិនថាគ្រួសារក្រីក្រ ឬ គ្រួសារអ្នកមាន។ ជាក់ស្ដែងការ លែងលះកើតមានឡើងនៅប្រទេសកម្ពុជា គូស្វាមីភរិយារមែងមានភាពមិនស្របជាមួយគ្នាទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិដែលក្នុងករណី ភាគច្រើន គឺជាទ្រព្យសម្បត្តិអចលនទ្រព្យ (ផ្ទះ ឬដី)។ មូលហេតុដែលបណ្ដាលឲមានកត្តាទាំងនេះ ព្រោះគូស្វាមីភរិយាភាគច្រើននៅក្នុងប្រទេសកម្ពុជា មិនមានកិច្ចព្រមព្រៀងកម្មសិទ្ធិអាពាហ៍ពិពាហ៍ជាផ្លូវការ (ស្របច្បាប់) ឬត្រូវបានគេស្គាល់ថាជាការ ចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមរយៈកិច្ចសន្យា)។

តើអ្វីជាកិច្ចព្រមព្រៀងទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ហើយតើវាមានសារៈសំខាន់យ៉ាងដូចម្ដេច?

ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមរយៈកិច្ចសន្យា ឬអាចហៅបានថាកិច្ចព្រមព្រៀងទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាជាលាយលក្ខណ៍អក្សរដែលបង្កើតឡើងដោយប្ដីប្រពន្ធមុន ឬក្រោយពួកគេរៀបអាពាហ៍ពិពាហ៍។[4] កិច្ចសន្យានេះចុះបញ្ជីទ្រព្យសម្បត្តិទាំងអស់ដែលបុគ្គលម្នាក់ៗមានមុនពេលរៀបអាពាហ៍ពិពាហ៍ហើយបញ្ជាក់ថា តើទ្រព្យសម្បត្តិណាខ្លះជាសិទ្ធិកម្មសិទ្ធិរបស់ បុគ្គលណាបន្ទាប់ពីអាពាហ៍ពិពាហ៍។

ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា គឺបានបញ្ជាក់យ៉ាងច្បាស់ពីការ កំណត់នូវសិទ្ធិ និងកាតព្វកិច្ច ព្រមទាំងការចាត់ចែងលើទ្រព្យសម្បត្តិរបស់សហព័ទ្ធជាដើម។ ហេតុនេះ ហើយទើបរាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែរិះរកគ្រប់មធ្យោបាយក្នុងគោលបំណងដើម្បីឲកិច្ចព្រមព្រៀងទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ មានភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិនៃការលក់ទិញ ឬបែងចែកទ្រព្យសម្បត្តិនៅពេលដែលមានការលែងលះគ្នា ឬនៅពេល

[4] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា ៩៦៩

ភាគីម្ខាងបានចែកឋានទៅ។ ទ្រព្យសម្បត្តិ ដែលបានរៀបរាប់ខាងលើអាចមានច្រើនទម្រង់ក្នុងរូបភាពផ្សេងៗ ក៏ប៉ុន្តែទ្រព្យសម្បត្តិអចលនទ្រព្យ ដូចជាដី ផ្ទះ ឬ អគារមានភាពស្មុគស្មាញក្នុងការបែងចែកព្រោះតម្លៃអចលនទ្រព្យមិនមានភាពឋិតថេរ របៀតនោះទេ តម្លៃនៃអចលនទ្រព្យនីមួយៗភាគច្រើនតែងតែកើនឡើងទៅតាមតម្លៃទីផ្សារសេដ្ឋកិច្ច ឬអាចថយចុះក្នុងករណីតម្លៃនៃអចលនវត្ថុធ្លាក់ចុះដោយសង្កេតតាមតម្លៃទីផ្សារសេដ្ឋកិច្ច។

ដូចន្នេះហើយដើម្បីជៀសវាងវិវាទមួយនេះ ប្តីប្រពន្ធដែលត្រូវរៀបការត្រូវចុះបញ្ជីកិច្ចព្រមព្រៀងទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍នៅនាយកដ្ឋានកិច្ចការស៊ីវិលនៃក្រសួងយុត្តិធម៌ ធ្វើឡើងជាលាយលក្ខណ៍អក្សរដើម្បីអាចយកទៅតតាំងជាមួយនឹងតតិយជនបាន។ នាយកដ្ឋាននេះក៏ចុះបញ្ជីការផ្លាស់ប្តូរ និងការលុបកិច្ចព្រមព្រៀងទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ផងដែរ។ ការចុះកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនេះអាចធ្វើឡើងមុន ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍។ ដូច្នេះប្តីប្រពន្ធត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ដើម្បីជៀសវាងជម្លោះដែលមិនទាន់បានកើតឡើង។ ម៉្យាងទៀតកាតព្វកិច្ចរបស់ប្តី ឬប្រពន្ធក្នុងការសងបំណុលលើទ្រព្យសម្បត្តិក៏ចាំបាច់ផងដែរ។ ឧទាហរណ៍៖ ទាក់ទងនឹងប្រាក់ កម្ចីទិញផ្ទះភាគីទាំងពីរគួរកំណត់ឱ្យច្បាស់ថាតើប្រាក់កម្ចីទិញផ្ទះបានកើតឡើងមុន ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍អ្នកណានឹងត្រូវទទួលខុសត្រូវបន្ទាប់ពីការលែងលះ និងគិតជាភាគរយប៉ុន្មាន។ ដូច្នេះ កិច្ចព្រមព្រៀងទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍នឹងជួយគូស្វាមីភរិយាក្នុងការបំពេញភារកិច្ចទាំងនេះកាន់តែសាមញ្ញ។

### ១.៣.២ ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់កំណត់

ប្រទេសនីមួយៗសុទ្ធតែមានច្បាប់សម្រាប់ប្តីប្រពន្ធ ទាក់ទងទៅនឹងប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធ។ ដូចដែលយើងបានដឹងរួចមកហើយថា ក្រមរដ្ឋប្បវេណីខ្មែរទុកលទ្ធភាពឲ្យប្តីប្រពន្ធធ្វើកិច្ចសន្យាដើម្បីកំណត់ការបែងចែក និងការចាត់ចែងទ្រព្យសម្បត្តិតាមរយៈការចុះកិច្ចសន្យាគ្រប់គ្រង ប្រព័ន្ធទ្រព្យសម្បត្តិ ប៉ុន្តែប្រសិនបើប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិទេ ការបែងចែក គ្រប់គ្រង និងចាត់ចែងទ្រព្យគឺត្រូវធ្វើតាមច្បាប់ដែលបានកំណត់ ដែលគេហៅថាប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។

ការចុះកិច្ចសន្យាទ្រព្យសម្បត្តិរវាងសហព័ទ្ធគឺជាសកម្មភាពមួយដែលមានភាពច្បាស់លាស់ និងស្មើភាពគ្នានៅពេលដែលសហព័ទ្ធសម្រេចចិត្តលុបចោលអាពាហ៍ពិពាហ៍របស់ពួកគេ ព្រោះកម្មវត្ថុត្រូវបានចែងយ៉ាងច្បាស់លាស់នៅក្នុងកិច្ចសន្យា ប៉ុន្តែសម្រាប់ប្តីប្រពន្ធដែលមិនបានចុះកិច្ចសន្យា វិវាទនឹងកើតឡើងរវាងប្តីប្រពន្ធដោយសារតែគ្មានភស្តុតាងបញ្ជាក់ច្បាស់លាស់ពីកម្មសិទ្ធនៃ ទ្រព្យសម្បត្តិកោយពេលរៀបការ។ វិវាទកើតឡើង

ជានិច្ចជាកាលក្នុងអាពាហ៍ពិពាហ៍ដែលមិនបានចុះកិច្ចសន្យា ហើយការបែងចែកទ្រព្យសម្បត្តិក៏អាចមានភាពមិនស្មើគ្នាដោយសារតែការបែងចែក ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

យ៉ាងណាមិញ គោលការណ៍នៃប្រព័ន្ធនេះត្រូវបានចែងយ៉ាងលម្អិតនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងត្រូវបានអនុវត្តដោយស្វ័យប្រវត្តិនូវការកំណត់នូវសិទ្ធិ និងកាតព្វកិច្ចព្រមទាំងការចាត់ចែងលើទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលបានធ្វើការកំណត់សមត្ថកិច្ច ក្នុងការប្រើប្រាស់ គ្រប់គ្រង និងចាត់ចែងនេះលើទ្រព្យសម្បត្តិរបស់សហព័ទ្ធបានយ៉ាងច្បាស់លាស់។

## ១.៤ ប្រភេទនៃទ្រព្យសម្បត្តិសម្បត្តិរបស់សហព័ទ្ធ

ប្រទេសនីមួយៗនៅលើសកលលោកមានការបែងចែកច្បាប់ នៃទ្រព្យសម្បត្តិខុសៗគ្នា ចំណែកប្រទេសកម្ពុជាវិញការបែងចែកទ្រព្យសម្បត្តិមានលក្ខណៈផ្សេងពីគ្នា។ ការបែងចែកទ្រព្យសម្បត្តិអាស្រ័យនឹងប្រព័ន្ធទ្រព្យសម្បត្តិដែលប្តីប្រពន្ធទាំងពីរជ្រើសរើសដើម្បីជៀសវាងវិវាទរវាងសហព័ទ្ធ ដោយមានការបែងចែកប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមរយៈកិច្ចសន្យា និងប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមច្បាប់កំណត់។

ដោយយោងទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ប្រភេទនៃទ្រព្យសម្បត្តិរបស់សហព័ទ្ធត្រូវបានបែងចែកចេញជាពីរ ប្រភេទគឺ៖

### ១.៤.១ ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដាច់ដោយឡែកសំដៅទៅលើទ្រព្យដែលជាកម្មសិទ្ធិរបស់សហព័ទ្ធតែម្ខាង (ប្តី ឬប្រពន្ធ) ដែលមានមុនអាពាហ៍ពិពាហ៍ដែលទ្រព្យទាំងនោះអាចជា អចលនទ្រព្យ និងចលនទ្រព្យ។[5] ក្នុងប្រព័ន្ធនេះ ប្តីប្រពន្ធមានសិទ្ធកាន់កាប់ និងគ្រប់គ្រងទ្រព្យសម្បត្តិរៀងៗខ្លួនផ្ទាច់មុខ ហើយយោងទៅតាមក្រមរដ្ឋប្បវេណី មាត្រា ១២០ បានកំណត់នូវនិយមន័យនៃទ្រព្យសម្បត្តិទាំងពីរនេះថា៖

[5] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា ៩៧២

– **អចលនទ្រព្យ៖**

សំដៅទៅលើ ដីធ្លី វត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងទៅតាមចិត្តរបស់ កម្មសិទ្ធិករបានទេដូចជា អាគារ សំណង់ ដំណាំ រុក្ខជាតិជាអាទិ៍។[6]

– **ចលនទ្រព្យ៖**

សំដៅទៅលើទ្រព្យសម្បត្តិទាំងឡាយដែល ក្រៅពីអចលនទ្រព្យ ដែលអាចផ្លាស់ប្តូរទីកន្លែង ទៅតាមចិត្តរបស់កម្មសិទ្ធិករបាន។ ឧទាហរណ៍៖ ដូចជា ឡាន ម៉ូតូ កង់ជាដើម។[7]

ទ្រព្យសម្បត្តិដាច់ដោយឡែកមានក្នុងទម្រង់ច្រើនប្រភេទដែលបុគ្គលប្តី ឬប្រពន្ធទទួលបានក្នុងរូបភាពផ្សេងៗគ្នាដូចជា (1) **ប្រទានកម្ម** (2) **អច្ច័យទាន** និង (3) **សន្តតិកម្ម**ជាដើម។[8]

**(1) ប្រទានកម្ម**

សំដៅ ទៅលើកិច្ចសន្យាមួយដែលត្រូវមានអានុភាពដោយភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ ទៅឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល។[9] ប្រទានកម្ម គឺជាកិច្ចសន្យាដែលជនម្នាក់ហៅថាអ្នកឱ្យ ឬទាយកផ្ទេរនូវកម្មសិទ្ធិនៃទ្រព្យរបស់ខ្លួនឱ្យទៅជនម្នាក់ទៀតហៅថាអ្នកទទួល ឬបដិគ្គាហកដែលព្រមទទួលយកទ្រព្យនោះ។

ឧទាហរណ៍៖ នារី "ខ" បានទទួលផ្ទះដូលបីល្វែងពីម្តាយឪពុករបស់នាង ជាអំណោយសម្រាប់ថ្ងៃ កំណើត។

**(2) អច្ច័យទាន**

អច្ច័យទាន គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬ ច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈ មតកសាសន៍។

---

[6] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា ១២០, ចំណុចទី២

[7] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា ១២០, ចំណុចទី៣

[8] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា ៩៧២, ចំណុច ខ

[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា ៥៦៨

ឧទាហរណ៍៖ នារី "ខ" បានទទួលនូវផ្ទះវីឡាភ្លោះចំនួន២នៅបូរីបេងហួតបឹងស្នោពីមីងរបស់នាងតាមរយៈការធ្វើបណ្តាំមរតកនៅមុនពេលដែលគាត់បានចែកឋានទៅ។

### (3) សន្តតិកម្ម

សន្តតិកម្ម គឺជាការប្រគល់ទ្រព្យសម្បត្តិទាំងឡាយណាដែលបានបន្សល់ទុកដោយ របស់មតកជន (ជនដែលបានស្លាប់) ទៅឲ្យ សន្តតិជនម្នាក់ ឬ ច្រើននាក់។[10] សន្តតិកម្មត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬដោយផ្អែកតាមឆន្ទៈរបស់មតកជនដែលសន្តតិកម្មដោយផ្អែកតាម បញ្ញត្តិច្បាប់ ហៅថាសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជនហៅថា សន្តតិកម្មមានបណ្តាំ។

ឧទាហរណ៍៖ លោក "ក" និង នារី "ខ" មានកូនចំនួន ៤នាក់ គឺ "គ" "ឃ" "ង" និង "ច"។ ក្រោយមក លោក "ក" (ឪពុក) ក៏បានស្លាប់ ហើយសល់ទឹកប្រាក់ចំនួន ១លានដុល្លារ។ ដូច្នេះ លោក "ក" គឺជាមតកជន នារី "ខ" (ម្តាយ) និង កូនទាំង ៤នាក់ទៀត (គ ឃ ង និង ច) គឺជាសន្តតិជន ហើយទឹកប្រាក់ចំនួន ១លានដុល្លារគឺជាមត៌ក (ទ្រព្យសម្បត្តិជាកេរទាំងឡាយដែលមតកជនបានបន្សល់ទុកក្រោយពេលស្លាប់)។ មត៌កទាំងអស់នេះនឹងត្រូវចែកស្មើៗគ្នាទៅឱ្យសន្តតិជន ប្រសិនបើរកឃើញថាមិនមាន បណ្តាំមត៌ក។

ទោះបីជាទ្រព្យសម្បត្តិដោយឡែកមានភាពខុសប្លែកគ្នាខ្លះអំពីការកំណត់នៅក្នុងប្រទេស និងរដ្ឋផ្សេងៗប៉ុន្តែច្បាប់ទម្រង់ទូទៅដូចគ្នាត្រូវបានអនុវត្ត។ ទម្រង់ទូទៅបំផុតនៃទ្រព្យសម្បត្តិដាច់ដោយ ឡែកគឺ ៖

### (១) ទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធមានមុនរៀបអាពាហ៍ពិពាហ៍

ឧទាហរណ៍៖ លោក "ក" បានធ្វើការសន្សំប្រាក់ដែលបានមកពីការងារ និងការធ្វើអាជីវកម្មផ្សេងៗ ចំនួន ១០០០០០ដុល្លា។ បន្ទាប់មកលោក "ក" ក៏បានសម្រេចចិត្តទិញផ្ទះមួយល្វែងដោយប្រើប្រាស់ប្រាក់សន្សំរបស់លោកចំនួន ៧០០០០ដុល្លា ដើម្បីមកទិញផ្ទះ រីឯប្រាក់សន្សំដែលលោកនៅសល់លោកបានដាក់ចូលទៅក្នុងគណនីធនាគារផ្ទាល់ខ្លួនមុនពេលលោករៀបការជាមួយនារី "ខ" ម្នាក់។ ដោយសារការទិញផ្ទះ និងប្រាក់សន្សំរបស់លោក "ក" កើតឡើងមុនពេលលោក "ក" រៀបអាពាហ៍ពិពាហ៍មានន័យថាផ្ទះ និងប្រាក់

[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា ១១៤៥

សន្សំដែលលោក "ក" បានចាត់ចែងគឺជាទ្រព្យសម្បត្តិ របស់លោក "ក" តែម្នាក់ប៉ុណ្ណោះមិនមែនជាទ្រព្យរួម ឡើយ។

**(២) អំណោយ និងមរតកដែលទទួលបានដោយប្ដី ឬប្រពន្ធមុនពេលឬអំឡុងពេល អាពាហ៍ពិពាហ៍ (តាមរយៈដូចជា ប្រទានកម្ម សន្ដតិកម្ម អច្ច័យទានជាដើម)**

ឧទាហរណ៍១៖ នារី "ខ" ទទួលបានដីស្រែមួយហិចតាពីម្ដាយរបស់ខ្លួនដែលជាអំណោយសម្រាប់ នារី "ខ" ដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយលោក "ក" នៅក្នុងពេលឆាប់ៗខាងមុខ។ ក្រៅពីទទួលបានដីស្រែមួយហិចតាពីម្ដាយរបស់ខ្លួនហើយ នារី "ខ" ក៏បានទទួលរថយន្តមួយគ្រឿងពីឪពុករបស់ខ្លួនក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ផងដែរ។ ដូច្នេះ នារី "ខ" ទទួលបានដីស្រែមួយហិចតា និងរថយន្តមួយគ្រឿងយ៉ាងពេញសិទ្ធិដែលជាទ្រព្យសម្បត្តិដាច់ ដោយឡែក។

ឧទាហរណ៍២៖ ឪពុកម្ដាយរបស់នារី "ខ" បានទទួលមរណភាព ហើយបានបន្សល់ទុកនូវផ្ទះជួល មួយកន្លែងឲនារី "ខ" ជាកេរ។ ក្នុងករណីនេះ នារី "ខ" បានទទួលបានសិទ្ធិពេញលេញក្នុងការ គ្រប់គ្រងផ្ទះជួលនេះ ទោះបីជាការទទួលបានទ្រព្យកេរនេះកើតឡើងអំឡុងពេលអាពាហ៍ពិពាហ៍ ក៏ដោយ ក៏ទ្រព្យកេរនេះនៅតែគិតជាទ្រព្យសម្បត្តិដាច់ដោយឡែក មិនមែនជាទ្រព្យសម្បត្តិរួម នោះទេ។

**(៣) ទ្រព្យសម្បត្តិដែលជាតម្លៃតបពីការចាត់ចែងទ្រព្យសម្បត្តិពីចំណុច (១) និង (២)**

ឧទាហរណ៍១៖ នារី "ខ" បានទទួលផ្ទះជួលមួយកន្លែងដែលផ្ទះនេះខ្លួនទទួលបានតាមរយៈសន្តតិកម្មពីឪពុកម្ដាយរបស់ខ្លួន។ នារី "ខ" ក៏ទទួលបានចំណូលប្រចាំខែពីផ្ទះជួលដែលនាងបានពី ឪពុកម្ដាយមកនេះ។ ក្នុងករណីមួយនេះ មិនថានារី "ខ" បានប្រាក់ចំណូលពីផ្ទះជួលមុនពេល ឬក្រោយពេលអាពាហ៍ពិពាហ៍នោះទេ ផ្ទះជួល និងប្រាក់ចំណូលពីផ្ទះជួលដែលនារី "ខ" ទទួលបាន រាល់ខែ ក៏ត្រូវ ចាត់ទុកជាទ្រព្យដោយឡែកដែរ។

ឧទាហរណ៍២៖ លោក "ក" បានទិញដីស្រែមួយកន្លែងនៅខេត្តស្វាយរៀងមុនពេលលោកបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹង នារី "ខ"។ បន្ទាប់ពី លោក "ក" បានរៀបអាពាហ៍ពិពាហ៍ គាត់ក៏សម្រេចចិត្តលក់ដីស្រែដែលគាត់បានទិញនោះ ដើម្បីមកទិញដីមួយកន្លែងថ្មីដែលមានទីតាំងនៅភ្នំពេញ។ ក្នុងករណីនេះទោះបីជា លោក "ក" បានលក់ដីស្រែរបស់គាត់ហើយទិញដីមួយទៀតក្រោយពេលរៀបអាពាហ៍ពិពាហ៍

ក៏ដោយ ក៏ប្រាក់ដែលគាត់ទទួលបានពីការលក់ដី និងដីថ្មីដែលគាត់បានទិញក៏នៅតែចាត់ទុកថាជាទ្រព្យដាច់ដោយឡែក មិនមែនជាទ្រព្យសម្បត្តិរួមនោះទេ។

### ១.៤.២ ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួមសំដៅទៅលើទ្រព្យសម្បត្តិតាំងឡាយណាដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងដែលទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។[11] អាស្រ័យហេតុនេះហើយ រាល់ទ្រព្យសម្បត្តិដែលកើតឡើងក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ចាត់ទុកជាទ្រព្យរួមលើកលែងតែទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធទទួលបានពី ប្រទានកម្ម អច្ច័យទាន និងសន្តតិកម្មដែលមិនរាប់ចូលជាទ្រព្យសម្បត្តិរួម។ និយាយជារួម លើកលែងតែទ្រព្យសម្បត្តិទាំងបីប្រភេទខាងលើ (ប្រទានកម្ម អច្ច័យទាន និងសន្តតិកម្ម) រាល់ទ្រព្យទាំងអស់ ដែលបានកើតលើងក្នុងពេលអាពាហ៍ពិពាហ៍មានដូចជាៈ

- **ប្រាក់ប្រចាំខែដែលបានមកពីការងារ**

ឧទាហរណ៍ៈ លោក "ក" មានការងារជាសាស្ត្រាចារ្យនៅសកលវិទ្យាន័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ជារៀងរាល់ខែ លោក "ក" ទទួលបានប្រាក់ចំណូលពីការបង្រៀនរបស់ គាត់ចំនួន ១000ដុល្លា។ ចំណែកឯនារី "ខ" ដែលជាប្រពន្ធរបស់លោក "ក" មានអាជីពជាអ្នកនិពន្ធ និងកែសម្រួលសៀវភៅភាសាអង់គ្លេស ដែលប្រាក់ចំណូលប្រចាំខែរបស់នាងចំនួន ១៥00ដុល្លា។ ប្រាក់ចំណូលរបស់ លោក "ក" និង នារី "ខ" ចាត់ទុកជាទ្រព្យសម្បត្តិរួមព្រោះបុគ្គលទាំងពីរគឺជា ប្តីប្រពន្ធនឹងគ្នា ហើយប្រាក់ចំណូលដែលបុគ្គលទាំងពីររកបានគឺនៅក្នុងអំឡុងពេលពាហ៍ពិពាហ៍។

- **ផលដែលកើតចេញពីទ្រព្យសម្បត្តិរួម**

ឧទាហរណ៍ៈ នៅពេលលោក "ក" និងនារីបានរៀបអាពាហ៍ពិពាហ៍ បុគ្គលទាំងពីរបានទទួលអំណោយជាខុនដូមួយកន្លែងដែលមានទីតាំងនៅកណ្តាលទីក្រុងភ្នំពេញ ពីឪពុកម្តាយរបស់លោក "ក" សម្រាប់ អាពាហ៍ពិពាហ៍របស់បុគ្គលទាំងពីរ។ ខុនដូមួយកន្លែងនេះទទួលបានប្រាក់ចំណូល ចំនួន១0000ដុល្លាជារៀងរាល់

[11] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា ៩៧៣

ពីការជួល។ ដូច្នេះប្រាក់ចំណូលចំណូលដែលបានពីការជួល និងអគារខុនដូគឺជាទ្រព្យសម្បត្តិរួមព្រោះលោក "ក" និងនារី "ខ" បានទទួលខុនដូជាកាដូពី ឪពុកម្ដាយរបស់ លោក "ក" ដោយពួកគាត់បានបញ្ជាក់យ៉ាងច្បាស់ថាសម្បត្តិអចលនទ្រព្យមួយ នេះគឺសម្រាប់បុគ្គល ទាំងពីរមិនមែនចំពោះបុគ្គលតែម្នាក់។

– **ចលនវត្ថុ ឬអចលនវត្ថុដែលបានទិញក្នុងអំឡុងអាពាហ៍ពិពាហ៍**

ឧទាហរណ៍១៖ បន្ទាប់ពីលោក "ក" និងនារី "ខ" បានរៀបអាពាហ៍ពិពាហ៍អស់រយៈពេលមួយឆ្នាំ លោក "ក" ក៏មានប្រាក់គ្រប់គ្រាន់ដែលបានមកពីសន្សំប្រាក់ប្រចាំខែដែលគាត់បានពីការធ្វើការ ដើម្បីមកទិញចំការមួយកន្លែងនៅខេត្តមណ្ឌលគិរី។ ចំការមួយកន្លែងនេះចាត់ទុកជាទ្រព្យសម្បត្តិរួមព្រោះការទិញមួយនេះស្ថិតក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍។

ឧទាហរណ៍២៖ ក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍លោក "ក" និងនារី "ខ" មានប្រាក់ចំណូលប្រចាំខែផ្ទាល់ខ្លួន។ លោក "ក" បានឃើញផ្ទះមួយកន្លែងក្នុងបុរីមួយដែលមានតម្លៃសមរម្យ។ ដោយសារតែសព្វថ្ងៃ លោក "ក" និងនារី "ខ" រស់នៅផ្ទះជាមួយឪពុកម្ដាយនៅឡើយ បុគ្គលទាំងពីរក៏សម្រេចចិត្តទិញផ្ទះក្នុងបុរីនោះដោយប្រើប្រាក់ដែលខ្លួនមានមកបញ្ចូលគ្នាដើម្បីទិញផ្ទះនោះ។

# ជំពូកទី២ ការកែតម្រូវ ផ្លាស់ប្តូរ និងការបញ្ចប់ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធ

អាពាហ៍ពិពាហ៍គឺជាជំហានដំបូងនៃការចាប់ផ្តើមគ្រួសារ រវាងមនុស្សប្រុសស្រីនៅពេលដែលបុគ្គលទាំងពីររូបសម្រេចចិត្តចាប់ដៃគ្នាដើម្បីបន្តជីវិតជាមួយគ្នាក្នុងនាមជាស្វាមី និងភរិយា។ ដូចដែលយើងបានសិក្សាមកខាងលើនេះ ក្នុងនាមជាសហព័ទ្ធទ្រព្យសម្បត្តិគឺជាផ្នែកដ៏ធំមួយក្នុងជីវិតជាគ្រួសារ។ គូរស្វាមីភរិយាខ្លះមានភាពយោគយល់គ្នាទៅវិញទៅមកក្នុងនាមជាប្តីប្រពន្ធ ប៉ុន្តែខ្លះទៀត ក៏មានវិវាទក្នុងគ្រួសារដែលពួកគេមិនយល់ស្របគ្នាក្នុងការបញ្ចេញមតិធ្វើឲមានការឈ្លោះទាស់ទែងគ្នា។ សហព័ទ្ធពុំអាចមើលឃើញថាស្ថានភាពរបស់បុគ្គលទាំងពីរទៅជាយ៉ាងណានោះទេនៅពេលអនាគត ហើយដោយសារតែកត្តាក្នុងគ្រួសារបែបនេះទើបមានការបែងចែកយ៉ាងច្បាស់លាស់ក្នុងក្រមរដ្ឋប្បវេណីស្តីពីប្រភេទនៃទ្រព្យសម្បត្តិ និងការបែងចែកទ្រព្យសម្បត្តិ។ នៅពេលដែលមានករណីដែលសហព័ទ្ធចង់កែប្រែ ឬបញ្ចប់ប្រព័ទ្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធ យើងត្រូវសិក្សាលើប្រភេទអាពាហ៍ពិពាហ៍នៃសហព័ទ្ធនោះជាមុនសិនថា តើអាពាហ៍ពិពាហ៍របស់បុគ្គលដែលចង់កែប្រែ ឬបញ្ចប់នោះស្ថិតក្នុងលក្ខខណ្ឌមួយណា។

## ២.១ ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា

ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្លុះបញ្ចាំងអំពីគោលគំនិតដែលបង្កប់នៅក្នុងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ កិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធមានផលប្រយោជន៍ច្រើនសម្រាប់គូស្វាមីភរិយាក្នុងការមានភាពច្បាស់លាស់ទាក់ទងនឹងសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិរបស់សហព័ទ្ធមាននៅពេលរៀបការរួច។ យ៉ាងណាក្តី ការការប្រែ ផ្លាស់ប្តូរក្នុងកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិតែងតែមាននៅពេលដែលបុគ្គលសហព័ទ្ធមានការផ្លាស់ប្តូរចិត្ត។ ក្រោយពេលចុះកិច្ចសន្យាហើយ ប្រសិនបើភាគីណាមិនពេញចិត្តទៅលើលក្ខខណ្ឌដែលបានចែងក្នុងកិច្ចសន្យាហើយមានបំណងចង់បំពេញបន្ថែមទៅលើចំណុចណាមួយ ភាគីទាំងសងខាងមានសិទ្ធិក្នុងការ កែតម្រូវឬផ្លាស់ប្តូរបាន។ ទោះបីជាសហព័ទ្ធអាចកែប្រែ ផ្លាស់ប្តូរចំណុចក្នុងកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិបានក៏ពិតមែន ប៉ុន្តែការកែប្រែ ឬ ផ្លាស់ប្តូរនេះត្រូវតែមានការយល់ព្រមពីសហព័ទ្ធម្ខាង ទៀតដែលជាប្តី រឺប្រពន្ធ។ ប្រសិនបើគ្មានការយល់ព្រមពីសំណាក់ភាគីម្ខាងទៀតនោះទេ កិច្ចសន្យា ប្រព័ន្ធទ្រព្យសម្បត្តិក៏មិនអាចធ្វើការផ្លាស់ប្តូរបានដែរ។ ការផ្លាស់ប្តូរ ការកែរតម្រូវកិច្ចសន្យា និងការបញ្ចប់ កិច្ចសន្យាមានលក្ខណៈខុសៗគ្នាៈ

### ២.១.១ ការផ្លាស់ប្តូរកិច្ចសន្យា

ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិកើតឡើងនៅពេលសហព័ទ្ធបានចុះបញ្ជីហើយ បុគ្គលណាមួយចង់ផ្លាស់ប្តូរ ចំណុចណាមួយក្នុងកិច្ចសន្យា។ ដូចដែលបានបញ្ជាក់នៅផ្នែកខាងលើនេះការកែប្រែ ឬ ផ្លាស់ប្តូរនេះត្រូវតែមានការយល់ព្រមពីសហព័ទ្ធម្ខាង ទៀតដែលជាប្តី រឺ ប្រពន្ធជាមុនសិន។

ឧទាហរណ៍៖ បន្ទាប់ពីលោក "ក" និង នារី "ខ" បានរៀបអាណាហ៍ពិពាហ៍រួចហើយបុគ្គលទាំងក៏បានសម្រេចចិត្តធ្វើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ នៅពេលចុះកិច្ចសន្យានោះ លោក "ក" បានបញ្ជាក់ប្រការមួយនៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថា៖ "រាល់តម្លៃតបដែលទទួលបានមកពីទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធត្រូវចាត់ទុកទ្រព្យសម្បត្តិនោះជាទ្រព្យសម្បត្តិដោយឡែក។" ប៉ុន្តែក្រោយពីបានចុះបញ្ជីរួចរាល់ហើយ នារី "ខ" មានការ ផ្លាស់ប្តូរចិត្តចំពោះប្រការដែលបានចែងដោយ លោក "ក" ហើយមានបំណងចង់ផ្លាស់ប្តូរវាទៅជាទ្រព្យសម្បត្តិរួមដោយគិតថា ក្នុងនាមជាប្តីប្រពន្ធធ្វើបែបនេះអាចជួយចែករំលែកបន្ទុកគ្រួសារចំពោះគ្នាទៅវិញទៅមក។ ដូចនេះ លោក "ក" និង នារី "ខ" បានព្រមព្រៀងគ្នាធ្វើពាក្យសុំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយបានផ្លាស់ប្តូរប្រការខាងលើទៅជា៖ "រាល់តម្លៃតបដែលទទួលបានមកពីទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធត្រូវចាត់ទុកទ្រព្យសម្បត្តិនោះជាទ្រព្យសម្បត្តិរួម។"

### ២.១.២ ការកែតម្រូវកិច្ចសន្យា

ការកែតម្រូវកិច្ចសន្យាសំដៅលើនៅពេលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវបានចុះបញ្ជីរួចហើយសហព័ទ្ធ ឬ អនាគតប្តីប្រពន្ធពិនិត្យឃើញថាមានកំហុស ឬ ខកខានមិនបានចុះបញ្ជីចំណុចណាមួយ អនាគតប្តីប្រពន្ធត្រូវដាក់ពាក្យសុំចុះបញ្ជីកែតម្រូវ។[12]

ការកែតម្រូវនេះត្រូវបានធ្វើឡើងនៅពេលដែលមានការខ្វះខាត ឬ មានភាពភាន់ច្រលំលើពត៌មានមួយចំនួនដូចជា៖

- ឈ្មោះ
- អាស័យដ្ឋាន
- ថ្ងៃ ខែ ឆ្នាំកំណើត

[12] ប្រកាសស្តីពីសន្តិវិធិនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, ប្រការ ២១

- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

នៅពេលមានការភាន់ច្រលំបែបនេះ សហព័ទ្ធអាចដាក់ពាក្យសុំចុះបញ្ជីអំពីកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិនោះ។ ការកែតម្រូវដែលទាក់ទងទៅនឹងអត្តសញ្ញាណរបស់បុគ្គលណាមួយគឺអាចធ្វើឡើងដោយបុគ្គល (ប្តី ឬ ប្រពន្ធ) តែម្ខាង។ ឧទាហរណ៍៖ លោក "ក" និង នារី "ខ" បានធ្វើការចុះកិច្ចសន្យាទ្រព្យសម្បត្តិបន្ទាប់ពីបុគ្គលទាំងពីរបានរៀបការរួច។ បន្ទាប់បីចុះកិច្ចសន្យាហើយ លោក "ក" បានឃើញ ថាឈ្មោះរបស់គាត់ត្រូវបានសរសេរខុស ដូច្នេះ លោក "ក" អាចដាក់ពាក្យស្នើសុំដើម្បីកែតម្រូវទាក់ទងនឹងការភាន់ច្រលំអក្ខរាវិរុទ្ធលើឈ្មោះរបស់គាត់បាន។

### ២.១.៣ ការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិ

ការបញ្ចប់កិច្ចសន្យាមានន័យថាជីវិតសហព័ទ្ធក្នុងនាមជាស្វាមី និងភរិយាឈានដល់ការបញ្ចប់។ ជាធម្មតា ជីវិតជាប្តីប្រពន្ធតែងតែមានភាពរង្គស់រង្គើប៉ុន្តែប្រសិនបើសហព័ទ្ធពិភាក្សាជាមួយគ្នា និងយល់ព្រមទៅលើដំណោះ ស្រាយពេលដែលមានវិវាទ នោះសហព័ទ្ធនឹងពុំអាចឈានទៅដល់ការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិរវាងសហព័ទ្ធនោះឡើយ។ នៅពេលសហព័ទ្ធបានចុះកិច្ចសន្យាទ្រព្យសម្បត្តិស្តីពីការគ្រប់គ្រងប្រព័ន្ធទ្រព្យសម្បត្តិ ការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិរវាងសហព័ទ្ធនឹងមានភាពងាយស្រួល ក្នុងការបែងចែកព្រោះក្នុងកិច្ចសន្យាដែលសហព័ទ្ធបានចុះគឺមានការបែងចែក និង ចារយ៉ាងច្បាស់លាស់នូវទ្រព្យសម្បត្តិ និងកិច្ចព្រមព្រៀងដែលបុគ្គលទាំងពីរបានយល់ព្រម។ ការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យា និងតាមច្បាប់កំណត់មិនមានលក្ខណៈខុសគ្នាឡើយ។ ហេតុផលនៃការបញ្ចប់កិច្ចសន្យាមានដូចជា៖

- ការលោយចំណងអាពាហ៍ពិហ៍ (ការលែងលះ)៖ ចំពោះការលោយចំណងអាពាហ៍ពិពាហ៍ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងទាក់ទិនទៅនឹងមូលហេតុដែលសហព័ទ្ធអាចដាក់ពាក្យបណ្តឹងលែងលះគ្នាទៅលើករណីដូចជា៖
  - អំពើផិតក្បត់
  - ការបោះបង់សហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវ
  - ការបាត់ខ្លួនរបស់សហព័ទ្ធដោយមិនដឹងថាប្តី ឬ ប្រពន្ធស្លាប់ រឺ រស់រយៈពេល ជាងមួយឆ្នាំ
  - សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង១ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍

  - ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។
  - ការលែងលះគ្នាសហាព័ទ្ធក៏អាចធ្វើឡើងបានផងដែរ ក្នុងករណីមានការព្រមព្រៀងគ្នារវាងសហាព័ទ្ធ។
- មោឃភាពអាពាហ៍ពិពាហ៍៖ ក្នុងករណីអាពាហ៍ពិពាហ៍បានធ្វើឡើងដោយគ្មានឆន្ទៈយល់ព្រមរៀបអាពាហ៍ពិពាហ៍ ការភ័ន្តច្រឡំលើបុគ្គល ការបង្ខំ និងមូលហេតុផ្សេងទៀត អាពាហ៍ពិពាហ៍នេះនឹងត្រូវបានចាត់ទុកជាមោឃៈ។[13] បន្ថែមពីនេះទៀត អាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយមិនបានដាក់ពាក្យសុំរៀបការ ឬ កង្វះខាតលើការជូនដំណឹងសាធារណៈអាពាហ៍ពិពាហ៍នោះក៏ត្រូវបានចាត់ទុកជាមោឃៈផងដែរ។
- ការលប់ចោលអាពាហ៍ពិពាហ៍៖ អាពាហ៍ពិពាហ៍ត្រូវបានលុបចោលក្នុងករណីដែលអាពាហ៍-ពិពាហ៍នោះមិនគោរពនូវលក្ខខណ្ឌដូចជា៖
  - មិនគោរពនូវលក្ខខណ្ឌនៃអាយុរៀបការ
  - ការបំពានលើលក្ខខណ្ឌដែលបានហាមឃាត់ចំពោះអាពាហ៍ពិពាហ៍រវាងញាតិ
  - ការហាមឃាត់មិនឲមានទ្វេពន្ធភាព
  - ការឆបោក ឬគំរាម
- មរណភាពនៃសហាព័ទ្ធ៖ មរណភាពរបស់ភាគីណាម្នាក់នៃសហាព័ទ្ធក៏ជាហេតុនាំឲ្យចំណងអាពាហ៍ពិពាហ៍ត្រូវបានរំលាយដែរ។

## ២.២ ការបញ្ចប់ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហាព័ទ្ធតាមច្បាប់កំណត់

ទំនាស់រមែងកើតមានក្នុងគ្រួសារនីមួយៗ ជាពិសេសនៅក្នុងពេលរៀបការ។ សម័យកាលផ្លាស់ប្តូរទៅតាមពេលវេលា មនុស្សក៏ផ្លាស់ប្តូរផ្នត់គំនិតទៅតាមពេលវេលានោះដែរ។ ដោយសារតែមនុស្សមានការផ្លាស់ប្តូរចិត្តបែបនេះហើយទើបមានសហាព័ទ្ធមួយចំនួនមានភាពមតិផ្ទុយពីគ្នាបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច។ សម្រាប់

[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា ៩៥៨

សហព័ទ្ធមួយចំនួន ពួកគេយល់ពីគ្នារហូតឈានទៅដល់ពេលវេលាមួយដែលពួកគេបញ្ចប់អាពាហ៍ពិពាហ៍របស់ដោយមូលហេតុធម្មជាតិ ប៉ុន្តែមួយផ្នែកទៀតសហព័ទ្ធមិនយោគយល់ពីគ្នារហូតដល់ឈានទៅដល់ការបញ្ចប់ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធ។ សហព័ទ្ធអាចបញ្ចប់ប្រព័ន្ធទ្រព្យសម្បត្តិរបស់ខ្លួនក្នុងករណីដូចជា៖

– **ការលែងលះ៖**

អាពាហ៍ពិពាហ៍អាចត្រូវបានបញ្ចប់តាមវិធីផ្សេងៗគ្នា ទៅតាមស្ថានភាពជាក់ស្តែងក្នុងគ្រួសារនីមួយៗ។ អាពាហ៍ពិពាហ៍ខ្លះអាចត្រូវដែលភាគីជាស្វាមីភរិយាមានវិវាទខាងផ្ទៃក្នុង ខ្លះទៀតក៏ដោយសារការស្លាប់របស់ដៃគូម្នាក់។ ការលែងលះដែលជារឿងធម្មតានៅក្នុងសង្គមសព្វថ្ងៃ ទោះជាយ៉ាងណាក៏ដោយទោះបីជាក្នុងករណីខ្លះការលែងលះ គឺជាដំណោះស្រាយតែមួយគត់សម្រាប់គ្រួសារមួយដើម្បីរស់នៅដោយសុខសាន្ត។ នៅពេលដែលជីវិតមិនអាចទ្រាំទ្របានរវាងស្ត្រីម្នាក់ និងស្វាមីរបស់ពួកគេពួកគេអាចគិតថាការលែងលះគឺជាដំណោះស្រាយត្រឹមត្រូវតែមួយគត់សម្រាប់ជីវិត។ យ៉ាងណាមិញទោះបីជាច្បាប់អនុញ្ញាតឲមានការលែងលះ ការលែងលះក៏ត្រូវមានហេតុផលត្រឹមត្រូវ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីមាត្រា ៩៧៨ ដូចជា៖

- អំពើផិតលើសហព័ទ្ធ៖ ក្នុងករណីបុគ្គលណាមួយ (ប្តី ឬ ប្រពន្ធ) លួចមានជនទីបីអំឡុងពេលអាពាហ៍ពិពាហ៍ សហព័ទ្ធដែលជាជនរងគ្រោះក្នុងអំពើផិតក្បត់អាចដាក់ពាក្យបណ្តឹងប្តឹងទៅតុលាការដើម្បីធ្វើការលែងលះបាន។

  ឧទាហរណ៍៖ លោក "ក" បានលួចសេបគប់ជាមួយនារីម្នាក់នៅកន្លែងធ្វើការរបស់គាត់ មិនឲនារី "ខ" ដែលជាប្រពន្ធដឹងនោះទេ។ លោក "ក" មានសម្ព័ន្ធភាពជាមួយនារីនោះដោយបានធ្វើការសេពសន្ថវៈផងដែរ។ ទោះបីជាលោក "ក" មិនបានបានធ្វើការសេពសន្ថវៈជាមួយនារីនោះក៏ទង្វើរបស់គាត់ចាត់ទុកជាការផិតក្បត់ដូចគ្នា។ នារី "ខ" ដែលជាប្រពន្ធបានដឹងរឿងនេះមានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីបញ្ចប់ អាពាហ៍ពិពាហ៍របស់នាង។

- ការបោះបង់សហព័ទ្ធ៖ ប្រសិនបើសហព័ទ្ធណាមួយ (ប្តី ឬ ប្រពន្ធ) បោះបង់ចោលសហព័ទ្ធមួយទៀតដោយគ្មានមូលហេតុត្រឹមត្រូវ សហពទ្ធដែលត្រូវបានគេបោះបង់នោះមានសិទ្ធិដាក់ពាក្យបណ្តឹងមកតុលាការដើម្បីដាក់ពាក្យលែងលះ។

  ឧទាហរណ៍៖ នារី "ខ" ដែលជាប្រពន្ធរបស់លោក "ក" រស់នៅជនបទអំឡុងពេលដែល លោក "ក" បានមកនៅភ្នំពេញដើម្បីធ្វើរកប្រាក់កម្រៃដើម្បីចិញ្ចឹមជីវិត។ លោក "ក" បានផ្ញើប្រាក់ឲប្រពន្ធរាល់ខែ

សម្រាប់ថ្លៃស្នាក់នៅប្រចាំថ្ងៃ។ នារី "ខ" បានបាត់ដំណឹងពី លោក "ក" អស់រយៈពេល ២ខែទើបនារី "ខ" សម្រេចចិត្តសួរដំណឹងលោក "ក" ពីអ្នក ធ្វើការជាមួយគាត់ នាងក៏បានដំណឹងថាលោក "ក" បានការងារថ្មី នៅបរទេសហើយ បានចាកចេញពីភ្នំពេញដោយមិនបានប្រាប់ នារី "ខ" នោះទេ។ រំលងអស់រយៈពេល មួយឆ្នាំ នារី "ខ" នៅតែមិនមានដំណឹងពីលោក "ក"។ ដូច្នេះហើយក្នុងករណីនេះ នារី "ខ" មានសិទ្ធិដាក់ពាក្យបណ្តឹងមកតុលាការដើម្បីដាក់ពាក្យលែងលះបាន។

- ការបាត់ខ្លួនរបស់សហព័ទ្ធ៖ ប្រសិនបើសហព័ទ្ធមួយណាបានបាត់ខ្លួន ហើយសហព័ទ្ធមួយទៀតមិនបានដឹងដំណឹងច្បាស់លាស់ពីការបាត់ខ្លួនរបស់សហព័ទ្ធថាស្លាប់ ឬ រស់អស់រយៈពេលជាងមួយឆ្នាំ សហព័ទ្ធដែលបានបាត់បង់សហព័ទ្ធរបស់ខ្លួននោះអាចដាក់ពាក្យបណ្តឹងមកតុលាការដើម្បីដាក់ពាក្យលែងលះបាន។

  ឧទាហរណ៍៖ លោក "ក" បានទៅធ្វើការជារៀងរាល់ថ្ងៃ ចំណែកនារី "ខ" ដែលជាប្រពន្ធនៅផ្ទះដើម្បីមើលថែកូន។ ជាធម្មតាលោក "ក" តែងតែមកផ្ទះវិញនៅម៉ោង៦ល្ងាច ប៉ុន្តែ លោក "ក" មិនទាន់បានមកដល់ផ្ទះទេ។ នារី "ខ" បានចាំផ្លូវលោក "ក" អស់រយៈ ពេលជាយូរ បន្ទាប់មកនារី "ខ" ក៏បានដាក់បណ្តឹងបាត់ខ្លួនរបស់ស្វាមីរបស់នាងប៉ុន្តែក៏មិនបានលឺដំណឹង។ នារី "ខ" បាត់ដំណឹងលោក "ក" អស់រយៈពេលជាងមួយឆ្នាំ។ ក្នុងករណីនេះ តុលាការអាចចេញសាលក្រមលែងលះឲនារី "ខ" បាន។

- ការរស់នៅបែកគ្នា៖ ក្នុងករណីសហព័ទ្ធរស់នៅបែកគ្នាក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ដោយសារមូលហេតុផ្សេងៗដូចជា មានទំនាស់ឈ្លោះគ្នាអស់រយៈពេលមួយឆ្នាំ សហព័ទ្ធម្ខាង (ប្តី ឬ ប្រពន្ធ) មានសិទ្ធិដាក់ពាក្យមកតុលាការដើម្បីធ្វើការលែងលះ។

  ឧទាហរណ៍៖ លោក "ក" និង នារី "ខ" មានជម្លោះជាមួយគ្នាទាក់ទងនឹងការចំណាយប្រចាំថ្ងៃក្នុងគ្រួសារ។ ដោយសារមូលហេតុនេះទើបនារី "ខ" បានទៅនៅជាមួយម្តាយរបស់នាងវិញអស់រយៈពេលជាងមួយឆ្នាំដោយគ្មានការផ្សះផ្សា។

- ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់៖ ក្នុងករណីចំណងអាពាហ៍ពិពាហ៍មួយដែលសហព័ទ្ធគ្មានភាពយល់ស្រប ឬ មានដំណោះស្រាយក្នុងអាពាហ៍ពិពាហ៍របស់ខ្លួនដោយសារបញ្ហាក្នុងចំណងអាពាហ៍ពិពាហ៍ធ្ងន់ធ្ងររហូតដល់មិនអាចផ្សះផ្សាមួយគ្នា។

ឧទាហរណ៍៖ បុរសជាប្តីរករឿងឈ្លោះគ្នាហើយស្រវឹងជារៀងរាល់ថ្ងៃ ថ្ងៃខ្លះវិញឈ្លោះគ្នារហូតដល់ថ្នាក់បោករបស់ប្រើប្រាស់ក្នុងផ្ទះដូចជា ចាន ឆ្នាំងជាដើម។

- ការលែងលះដោយការព្រមព្រៀង៖ សំដៅទៅលើការដាក់បណ្តឹលែងលះទៅតុលាការបាននៅពេលដែលសហព័ទ្ធទាំងសងខាងយល់ស្របនឹងគ្នាអំពីការលែងលះគ្នា។ ចំណងអាពាហ៍ពិពាហ៍ជាប្តីប្រពន្ធត្រូវបានបញ្ចប់ នៅពេលដែលភាគីទាំងសងខាងមិនអាចបន្តរស់នៅជាមួយគ្នាក្នុងនាមជាសហព័ទ្ធតទៅទៀត។ តុលាការនឹងចេញសេចក្តីសម្រេចឲសហព័ទ្ធលែងលះគ្នាបាននៅពេលដែលភាគីទាំងសងខាងបង្ហាញនូវគោលបំណងច្បាស់លាស់ នៃការបញ្ចប់ចំណងអាពាហ៍ពិពាហ៍។[14]

– **មរណភាព៖**

មនុស្សគ្រប់រូបចូលមករៀបអាពាហ៍ពិពាហ៍ដោយសង្ឃឹមថានឹងមាន ទំនាក់ទំនងយូរអង្វែងជាមួយគ្នាជាមួយដៃគូរបស់ខ្លួនរហូតដល់ថ្ងៃស្លាប់ ប៉ុន្តែក្នុងករណីដែលជាការសោកស្តាយបំផុតគឺសេចក្តីស្លាប់បំបែកពួកគេពីគ្នាទៅវិញ។ មរណភាពរបស់សហព័ទ្ធ (ប្តី ឬ ប្រពន្ធ) គឺជាកត្តាមួយដែលនាំឲមានការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ទោះបីជាសហព័ទ្ធម្ខាងដែលនៅមានជីវិតមិនចង់បញ្ចប់ក៏ដោយ ព្រោះចំណងអាពាហ៍ពិពាហ៍គឺរវាងមនុស្សពីរនាក់ ហើយមិនអាចមានតែសហព័ទ្ធតែម្ខាងបានឡើយ។

– **មោឃភាព និងការលុបចោលអាពាហ៍ពិពាហ៍៖**

អាពាហ៍ពិពាហ៍កើតឡើងបាននៅពេលដែលភាគីប្រុស និងស្រីយល់ព្រមសាងគ្រួសារជាមួយគ្នាប៉ុន្តែមោឃភាពនិងការលុបចោលអាពាហ៍ពិពាហ៍អាចកើតឡើងបានក្នុងរូបភាពផ្សេងៗគ្នាប្រសិនបើគេរក ឃើញនូវចំណុច ឬគោលបំណងនៃអាពាហ៍ពិពាហ៍នោះប្រព្រឹត្តិទៅក្នុងករណីវិការៈធ្ងន់ធ្ងរ ដោយយោងតាមក្រមរដ្ឋប្បវេណី មាត្រា ៩៥៨ លើនីតិវិធីរៀបអាពាហ៍ពិពាហ៍ដោយគ្មានឆន្ទៈ រៀបអាពាហ៍ពិពាហ៍រវាងភាគីដូចជា៖

- ការភាន់ច្រឡំលើមនុស្ស៖ សំដៅទៅលើករណីដែលភាគីមួយមានគោលបំណងក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយភាគីម្ខាងទៀត ក៏ប៉ុន្តែដោយមានការភ័ន្តច្រឡំមនុស្ស ម្នាក់ដែលមានរូបរាង

[14] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា ៩៧៩

លក្ខណៈសម្បត្តិដូចនឹងភាគីដែលខ្លួនគម្រោងនឹងធ្វើការរៀបការជាមួយ ក៏បានទៅរៀបអាពាហ៍ពិពាហ៍ជាមួយភាគីម្ខាងទៀត។ ករណីភាន់ច្រឡំលើមនុស្សនេះជាហេតុនាំឲ្យមានមោឃភាពអាពាហ៍ពិពាហ៍កើតមានឡើងនៅពេលដែលខ្លួនដឹងថាអាពាហ៍ពិពាហ៍នេះ គឺជាមួយមនុស្សដែលមិនមែនសមីខ្លួនជាអ្នកជ្រើសរើស។

ឧទាហរណ៍៖ បុរស "ក" បាននឹងធ្វើការរៀបការជាមួយ នារី "ខ" នៅថ្ងៃជាក់លាក់ណាមួយ។ ដោយនារី "ខ" មានប្អូនស្រីឈ្មោះ នារី "ត" ដែលត្រូវជាកូនភ្លោះជាមួយនឹងខ្លួន។ ដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍ បុរស "ក" បានរកឃើញថាខ្លួនមិនបានរៀបការជាមួយនារី "ខ" ទេតែការរៀបការនោះគឺជាមួយនឹងនារី "ត" ទៅវិញ។

- ការបង្ខំ៖ ក្នុងករណីអាពាហ៍ពិពាហ៍បានកើតឡើងដោយមាន ការបង្ខិតបង្ខំពីសំណាក់ ឪពុកម្តាយ អាណាព្យាបាល ឬ តតិយជនក្នុងការឲ្យភាគីម្ខាងនៃចំណងអាពាហ៍ពិពាហ៍នោះធ្វើការយល់ព្រមរៀបអាពាហ៍ពាហ៍ជាមួយភាគីម្ខាងទៀត។ ប្រសិន បើភាគីម្ខាងណាមិនបានយល់ព្រមក្នុងការរៀបអាពាហ៍ពិពាហ៍នោះទេ ហើយដោយហេតុថាមានការបង្ខំពីសំណាក់ក្រុមគ្រួសារឲធ្វើការយល់ព្រមនឹងចំណងអាពាហ៍ពិពាហ៍ដែលខ្លួនមិនពេញចិត្ត អាពាហ៍ពិពាហ៍នោះអាចត្រូវធ្វើការមោឃភាពបាន។

  ឧទាហរណ៍៖ នារី "ខ" មិនបាន ស្រលាញ់លោក "ក" ទេ ដោយសារតែនាងមានបុរសដែលនាងស្រលាញ់រួចមកហើយ ក៏ប៉ុន្តែដោយសារការបង្ខិតបង្ខំពីសំណាក់ឪពុកម្តាយរបស់នាង ដោយមានការគំរាម ធ្វើបាបលើរូបរាងកាយ និងផ្លូវចិត្តព្រមទាំងបង្អត់អាហារផងនោះ ទើបនាងបានយល់ព្រមក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយលោក "ក" នោះ។

# ជំពូកទី៣ ការបែងចែកទ្រព្យសម្បត្តិ និងភាតព្វកិច្ចរបស់សហព័ទ្ធ

នៅពេលដែលសហព័ទ្ធឈានការរំលាយអាពាហ៍ពិពាហ៍ ការបែងចែកទ្រព្យសម្បត្តិនិងកាតូកិច្ចរបស់បុគ្គលនីមួយៗក៏ត្រូវបានចែងដូចគ្នា។ ថ្វីត្បិតករណីរំលាយអាពាហ៍ពិពាហ៍ពុំមែនការអ្វីៗដែលប្តីប្រពន្ធប្រាថ្នាចង់បាន ប៉ុន្តែគ្មាននរណាម្នាក់អាចមើញថានឹងមានរឿងអ្វីកើតឡើងនោះឡើយ។ ប្រាកដណាស់នៅពេលដែលសហព័ទ្ធឈានការរំលាយអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិនឹងត្រូវបានចែកដោយយោងទៅតាមលក្ខខណ្ឌណាមួយដែលសហព័ទ្ធបានជ្រើសរើស។ ការចែកទ្រព្យសម្បត្តិមានភាពខុសៗគ្នាដោយយោងទៅតាមទម្រង់ដែលសហព័ទ្ធបានជ្រើសរើសថា តើអំឡុងពេលអាពាហ៍ពិពាហ៍សហព័ទ្ធបានចុះកិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិ ឬ ក៏ត្រូវបែងចែកទ្រព្យសម្បត្តិតាមច្បាប់កំណត់ (មិនបានចុះកិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិ)។ ការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធបែងចែកទៅតាមករណីដូចខាងក្រោមះ

## ៣.១ ការបែងចែកទ្រព្យសម្បត្តិតាមកិច្ចសន្យា

កិច្ចសន្យាទ្រព្យសម្បត្តិផ្តល់ផលប្រយោជន៍ដល់សហព័ទ្ធ ដែលមានបំណងចង់បែងចែកទ្រព្យសម្បត្តិក្នុងករណីដែលបុគ្គលទាំងពីរដាក់បណ្តឹងលែងលះចែកផ្លូវគ្នាជាប្តីប្រពន្ធ។ ទោះបីជាការបែងចែកទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យាមានភាពច្បាស់ក៏ពិតមែន ប៉ុន្តែកិច្ចសន្យានីមួយៗតែងតែមានភាពខ្វះខាត និងមិនគ្រប់ជ្រុងជ្រោយឡើយ។ ឆន្ទៈ និងគោលបំណងដែលសហព័ទ្ធបានចែងក្នុងកិច្ចសន្យាអាចមានភាពគ្លោះគ្លោយនៅពេលដែលបុគ្គលទាំងពីរលែងលះគ្នា វិវាទក៏នៅតែមានប៉ុន្តែចៅក្រមអាចរកនូវសន្តិវិធីដើម្បីដោះស្រាយភាពមិនយល់ស្របមួយនេះ។ ប្រសិនបើសហព័ទ្ធមិនមានបញ្ហា ឬចម្ងល់ទាក់ទងនឹងផ្នែកណាមួយដែលមិនបានចែងច្បាស់លាស់ក្នុងកិច្ចសន្យានោះទេ ចៅក្រមអាចកាត់ក្តីទៅតាមអ្វីដែលបានចែងក្នុងកិច្ចសន្យាដែលសហព័ទ្ធនោះតែម្តង។

## ៣.២ ការបែងចែកទ្រព្យសម្បត្តិតាមច្បាប់កំណត់

ផ្ទុយពីការបែងចែកទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យា ការបែងចែកទ្រព្យសម្បត្តិតាមច្បាប់កំណត់ ចៅក្រមត្រូវវិភាគឲបានច្បាស់លាស់ដោយសារការបែងចែកទ្រព្យសម្បត្តិតាមច្បាប់កំណត់ សហព័ទ្ធមិនមានភស្តុតាងជា

លាយលក្ខអក្សរដើម្បីមកបញ្ជាក់នោះទេ។ មុននឹងធ្វើការបែងចែកទ្រព្យសម្បត្តិ តាមច្បាប់កំណត់ថាក្រមត្រូវធ្វើការត្រួតពិនិត្យលើចំណុចដូចជាការព្រមព្រៀងពីសហព័ទ្ធ និងសេចក្តី សម្រេចរបស់តុលាការ។[15]

### ៣.២.១ ការព្រមព្រៀងពីសហព័ទ្ធ

សហព័ទ្ធអាចធ្វើការកំណត់ក្នុងការបែងចែកទ្រព្យសម្បត្តិរាល់ ចំណុចណាមួយដែលខ្លួនគិតថាភាគីម្ខាងទៀតមានចំណែកច្រើនជាង ហើយគិតថាមិនស្មើភាពគ្នាដោយមានការព្រមព្រៀងពីភាគីទាំងសង។ សហព័ទ្ធអាចព្រៀងទុកជាមុននូវអ្វីដែលខ្លួនចង់បែងចែកក្នុងទ្រព្យសម្បត្តិ បន្ទាប់មកតុលាការនឹងធ្វើការសម្រេចលើការបែងចែកទ្រព្យសម្បត្តិ ទៅតាមអ្វីដែលភាគីទាំងសងខាងបានព្រមព្រៀងទុករួចហើយនោះ។

ឧទាហរណ៍៖ លោក "ក" និង នារី "ខ" បានទទួលខុនដូ និងដីមួយកន្លែងនៅភ្នំពេញពីឪពុក ម្តាយរបស់លោក "ក" ជាចំណងដៃថ្ងៃអាពាហ៍ពិពាហ៍។ ដោយសារតែការរស់នៅមិនចុះសម្រុង នឹងគ្នា លោក "ក" និង នារី "ខ" ក៏សម្រេចចិត្តលែងលះគ្នាដោយលោក "ក" យល់ព្រមនឹង ការទាមទារខុនដូដែលជាទ្រព្យរួមឲទៅនារី "ខ"។

### ៣.២.២ សេចក្តីសម្រេចរបស់តុលាការ

សហព័ទ្ធអាចធ្វើការបែងចែកទ្រព្យរួមដោយការព្រមព្រៀងជាមុនសិន។ ប្រសិនបើគ្មានការព្រមព្រៀងទេនោះសហព័ទ្ធម្នាក់ៗត្រូវយកតែទ្រព្យសម្បត្តិដែលខ្លួនបានទទួលជាមត៌កភក្តី ជាអំណោយក្តីជាអច្ច័យទានក្តីក្នុងរយៈមានចំណងអាពាហ៍ពិពាហ៍ប៉ុណ្ណោះ។[16] ក្រៅពីនេះការបែងចែកទ្រព្យរួមមើលទៅលើលក្ខណៈតាមក្រមរដ្ឋប្បវេណី មាត្រា ៩៨០ បានចែងថា៖

- ការសម្គាល់មុខទ្រព្យសម្បត្តិ៖ ការសម្គាល់ទ្រព្យសម្បត្តិគឺជាដំណាក់កាលដំបូងនៃ ការបែងចែកទ្រព្យសម្បត្តិ។ តើទ្រព្យនោះជាចលនទ្រព្យ ឬអចលនអចលនទ្រព្យ។ ការយល់ដឹង និងសម្គាល់មុខទ្រព្យសម្បត្តិនេះគឺដើម្បីកុំឲមានមន្ទិលក្នុងការបែងចែកទ្រព្យសម្បត្តិ។ ក្រៅពីការសម្គាល់ចលនទ្រព្យ ឬ អចលនទ្រព្យហើយនៅពេលដែលសហព័ទ្ធបែងចែកទ្រព្យ ទ្រព្យដែលបុគ្គលទាំងពីរទទួលបានអាចជា ទ្រព្យរូបី ឬ ទ្រព្យអរូបី។ ទ្រព្យរូបី និង ទ្រព្យអរូបីសំដៅទៅលើ៖
    - ទ្រព្យរូបី៖ គឺជាទ្រព្យដែលមើលអាចឃើញ ឬ ប៉ះបានដូចជាឡាន ផ្ទះជាដើម។

---

[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា ៩៧៦

[16] ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ, មាត្រា ៧០

- ទ្រព្យអរូបី៖ គឺជាទ្រព្យដែលមើលមិនឃើញ ឬ ប៉ះបានប៉ុន្តែក៏នៅតែផ្តល់តម្លៃហិរញ្ញវត្ថុដូចជាប៉ាតង់ជាដើម។

- ការចាត់ប្រភេទនៃទ្រព្យសម្បត្តិ៖ ការចាត់ប្រភេទនៃទ្រព្យសម្បត្តិនេះសំដៅទៅលើការមើលទៅលើទ្រព្យសម្បត្តិណាជាទ្រព្យរួម និងទ្រព្យណាខ្លះជាទ្រព្យដាច់ដោយឡែក។ ជាទូទៅទ្រព្យរួម និងទ្រព្យដាច់ដោយឡែកមានការបែងចែកយ៉ាងច្បាស់លាស់តាមក្រមរដ្ឋប្បវេណី ប៉ុន្តែក៏មានករណីមួយចំនួនដែលធ្វើឲការបែងចែកមានភាពលំបាក។

  ឧទាហរណ៍៖ មុនពេលរៀបអាពាហ៍ពិពាហ៍ នារី "ខ" ទទួលបានផ្ទះមួយកន្លែងតាមរយៈប្រទានកម្មពីម្តាយរបស់នាង។ ផ្ទះរបស់នារី "ខ" ដែលទទួលបានមានតម្លៃត្រឹម តែ២០០០០ដុល្លាប៉ុណ្ណោះដោយសារតែផ្ទះនោះមិនទាន់មានការជួសជុសហើយក៏មានទីតាំងនៅជាយក្រុង។ បន្ទាប់មក នារី "ខ" ក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹង លោក "ក"។ ក្រោយពីការរៀបអាពាហ៍ពិពាហ៍ នារី "ខ" និង លោក "ក" បានខិតខំប្រឹងប្រែងក្នុងការជួលជុល និងកែលម្អផ្ទះនោះ។ បន្ទាប់ពីការរៀបចំឡើងថ្មីផ្ទះនោះហើយ តម្លៃទីផ្សារសេដ្ឋកិច្ចនៅជាយក្រុងក៏បានឡើងខ្ពស់ដោយសារភាគរយកើនឡើងនៃការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនមកជាយក្រុង។ តម្លៃផ្ទះដែលធ្លាប់មានតម្លៃទីផ្សារត្រឹម ២០០០០ដុល្លា បានកើនឡើងរហូតដល់ ១៥០០០០ដុល្លា។ ក្នុងករណីបែបនេះ នៅពេលដែល នារី "ខ" និង លោក "ក" លែងលះគ្នា តើផ្ទះដែលជាទ្រព្យសម្បត្តិដាច់ដោយឡែករបស់ នារី "ខ" នឹងត្រូវធ្វើការសម្រេច ដូចម្តេច? តើផ្ទះនោះនៅជាទ្រព្យសម្បត្តិដាច់ដោយឡែករបស់ នារី "ខ" ដដែល ឬ ផ្ទះនោះក្លាយជាទ្រព្យសម្បត្តិរួមវិញ?

- ការវាយតម្លៃទ្រព្យសម្បត្តិ៖ ការវាយតម្លៃទ្រព្យសម្បត្តិគឺជាចំណុចដ៏សំខាន់មួយដែលមិនអាចមើលរំលងបាននៅពេលធ្វើការបែងចែកទ្រព្យសម្បត្តិ។ ការវាយតម្លៃនេះ អាស្រ័យលើស្ថានភាពជាក់ស្តែងនូវតម្លៃទីផ្សារបច្ចុប្បន្ន ដើម្បីឲមានភាពស្មើគ្នាក្នុងការបែងចែកទ្រព្យសម្បត្តិជៀសវាងវិវាទរវាងបុគ្គល។

  ឧទាហរណ៍៖ លោក "ក" និង នារី "ខ" មានដីពីរកន្លែងដែលមួយនៅជាយក្រុង និងមួយទៀតនៅទីក្រុងភ្នំពេញ។ លោក "ក" ក៏ប្រគល់ដីនៅជាយក្រុងឲ នារី "ខ" ។ នារី "ខ" ក៏មិនសុខចិត្តដោយសារដីដែលនៅជាយក្រុងនោះមានទីតាំងឆ្ងាយពីទីក្រុង ហើយពុំអាចធ្វើអាជីវកម្មបាន

ណាមួយទៀតបើគិតតាមតម្លៃទីផ្សារបច្ចុប្បន្នដីនៅទីក្រុងមានតម្លៃថ្លៃជាងដីដែល លោក "ក" បានប្រគល់ឲ នារី "ខ" លើសបីដង។ ដោយសារតម្លៃទ្រព្យសម្បត្តិមិនស្មើភាពគ្នាបែបនេះ វិវាទរវាងការចែកទ្រព្យសម្បត្តិនឹងកើតឡើង។

- ការប្រគល់ទ្រព្យសម្បត្តិដោយឡែក៖ ទ្រព្យសម្បត្តិដាច់ដោយឡែកគឺជាទ្រព្យសម្បត្តិរបស់សហព័ទ្ធតែម្ខាង (ប្តី ឬ ប្រពន្ធ) ដែលរកបានមុនពេលរៀបអាពាហ៍ពិពាហ៍ ឬទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន និងតាមរយៈផ្សេងៗទៀត។ ក្នុងករណីនេះ ទ្រព្យសម្បត្តិដាច់ដោយឡែក ត្រូវប្រគល់ឲម្ចាស់ទ្រព្យវិញ។
- ការបែងចែកទ្រព្យរួម៖ ការបែងចែកទ្រព្យរួមត្រូវបានធ្វើឡើងលុះត្រាតែមានការយល់ព្រមរវាងសហព័ទ្ធជាមុនសិន។ ការបែងចែកទ្រព្យរួមគឺអាស្រ័យទៅលើស្ថានភាពដែលនាំឲសហព័ទ្ធឈានទៅដល់ការបែងចែកទ្រព្យសម្បត្តិរួម។ មូលហេតុ ទាំងនោះមានដូចជាការលែងលះ ការមានវិវាទភាពមិនសុខចិត្តរវាងការបែងចែក ទ្រព្យសម្បត្តិមិនស្មើភាពគ្នា និងកត្តាផ្សេងៗទៀត។

ការបែកចែកត្រូវបានធ្វើឡើង និងសម្រេចដោយតុលាការក្រោយពីបានសង្កេតមើលលក្ខខណ្ឌខាងលើនេះ។ ទោះជាយ៉ាងណាក្តីក៏មានករណីពិសេសខ្លះដែលបានកើតឡើងក្នុងស្ថានភាពជាក់ស្តែង ក្នុងសង្គមសព្វថ្ងៃដែលធ្វើឲការបែងចែកទ្រព្យសម្បត្តិមានភាពផ្លាស់ប្តូរក្នុងករណីដូចជា៖

**(១) ផលប្រយោជន៍របស់កូន (២) ការងារជាមេផ្ទះ (៣) អាយុ ស្ថានភាពផ្លូវកាយ និងចិត្ត (៤) លទ្ធភាពការងាររបស់ភាគី** និង **(៥) ការថែរក្សា និងបង្កើនទ្រព្យសម្បត្តិ**។[17]

**(១) ផលប្រយោជន៍កូន៖** នៅពេលដែលអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ ការបែងចែកទ្រព្យសម្បត្តិក៏ត្រូវមើលករណីពិសេសដូចជាផលប្រយោជន៍ដូចគ្នា។ ប្រសិនបើសហព័ទ្ធមានកូន សហព័ទ្ធដែលទទួលខុសត្រូវក្នុងការចិញ្ចឹមបីបាច់កូននោះ អាចទាមទារទ្រព្យសម្បត្តិច្រើនជាងសហព័ទ្ធម្ខាងទៀតបានដោយសម្អាងហេតុផលថាខ្លួនត្រូវចំណាយលើកត្តាផ្សេងៗដែលជាករណីពិសេស។

[17] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ មាត្រា ៩៨០ ចំណុចទី២ និង ៣

ឧទាហរណ៍៖ លោក "ក" និង នារី "ខ" បានសម្រេចលែងលះក្រោយពីបានរៀបការជាមួយគ្នាអស់រយៈពេល ១០ ឆ្នាំ។ អំឡុងពេលអាពាហ៍ពិពាហ៍ សហព័ទ្ធទាំងពីរបានទិញដីពីរកន្លែង និងមានប្រាក់សន្សំចំនួន ២០០០០០ដុល្លា។ នៅពេលដែលសហព័ទ្ធទាំងបែងចែកទ្រព្យសម្បត្តិ លោក "ក" ក៏បានបែងចែកទ្រព្យសម្បត្តិរួមជាពីរមានន័យថា នារី "ខ" ទទួលបានដីមួយកន្លែង និងប្រាក់ ១០០០០០ដុល្លា។ ប៉ុន្តែនារី "ខ" ទាមទារបន្ថែមទៀតដោយកហេតុផលចិញ្ចឹមកូនពីរនាក់ត្រូវចំណាយថវិការច្រើន។

(២) **ការងារជាមេផ្ទះ៖** ក្នុងសង្គមខ្មែរ មានភាគរយដែលប្រពន្ធមិនមានប្រាក់ចំណូលប្រចាំខែដោយសារត្រូវមើលការខុសត្រូវ និងថែផ្ទះសម្បែង។ ក្នុងករណីនេះប្តីគឺជាបុគ្គលតែម្នាក់ក្នុងគ្រួសារក្នុងការរកចំណូលដើម្បីចិញ្ចឹមគ្រួសារ។ នៅពេលដែលលែងលះគ្នា ក៏ប្រពន្ធមានចំណែកក្នុងការទទួលបានទ្រព្យសម្បត្តិរួមដែលប្តីរកបានអំឡុងពេលអាពាហ៍ពិពាហ៍ដែរ។ បើទោះបីជាស្ត្រីជាមេផ្ទះ មិនធ្វើការបានប្រាក់ខែមែន ក៏ប៉ុន្តែគាត់គឺជាអ្នករ៉ាប់រងកិច្ចការក្នុងផ្ទះ ដែលត្រូវរាប់ជាការងារមួយដែលមានតម្លៃដូចជាការងារក្រៅផ្ទះដែរព្រោះគេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ។

(៣) **អាយុ ស្ថានភាពផ្លូវកាយ និងចិត្ត៖** ករណីនេះគេមើលទៅលើអាយុបុគ្គលសហព័ទ្ធថាបុគ្គលមួយណា មានអាយុចាស់ជាង សុខភាពរឹងមាំទាំងផ្លូវកាយ និងផ្លូវចិត្តរឺទេ។ ប្រសិនបើបុគ្គលណាមួយមានលក្ខណៈ ដូចដែលបានរៀបរាប់ នោះការបែងចែកទ្រព្យសម្បត្តិក៏មើលទៅតាមស្ថានការផងដែរ។

(៤) **លទ្ធភាពការងាររបស់ភាគី៖** ករណីនេះសំដៅទៅលើលទ្ធភាពនៃការរកចំណូលប្រចាំខែនៃបុគ្គល។ ប្រសិនបើបុគ្គលម្នាក់នៃសហព័ទ្ធមានការលំបាក ក្នុងការរកចំណូលបានតិចជាងសហព័ទ្ធម្ខាងទៀតខ្លាំង ហើយសហព័ទ្ធម្ខាងទៀតគ្មានបញ្ហាក្នុងការរកចំណូល នោះការបែងចែកទ្រព្យសម្បត្តិក៏គិតទៅតាមករណីនោះដែរ។

ឧទាហរណ៍៖ លោក "ក" ជាអ្នកជំនួញខាងផលិតទឹកបរិសុទ្ធ ចំណែកនារី "ខ" ដែលជាប្រពន្ធមានការងារជាអ្នកកាត់ដេរ។ នៅពេលដែលបុគ្គលទាំងពីរសម្រេចចិត្តលែងលះគ្នា តុលាការអាចបែងចែកទ្រព្យសម្បត្តិឲទៅនារី "ខ" លើស លោក "ក" ដោយសារលោក "ក" អាចរកប្រាក់ចំណូលបានយ៉ាងងាយស្រួល ផ្ទុយពីនារី "ខ"។

(៥) **ការថែរក្សា និងបង្កើនទ្រព្យសម្បត្តិ៖** ក្នុងអំឡុងពេលរៀបការប្រសិនបើបុគ្គលណាមិនចេះថែរក្សា មិនជួយបង្កើនទ្រព្យសម្បត្តិទេ ថែមទាំងបំផ្លាញទ្រព្យសម្បត្តិទៀតនោះតុលាការនឹងធ្វើការបែងចែកទៅតាមករណីផងដែរ។

ឧទាហរណ៍៖ នារី "ខ" ដែលជាប្រពន្ធរបស់លោក "ក" បានខិតខំប្រឹងប្រែងរកប្រាក់ដើម្បីចិញ្ចឹមជីវិតប្រចាំថ្ងៃ។ ចំណែកលោក "ក" វិញមិនបានជួយរកអ្វីនោះទេ ថែមទាំងបំផ្លិតបំផ្លាញទ្រព្យសម្បត្តិដោយសារការលេងល្បែងផងដែរ។ នៅពេលលែងលះ តុលាការនឹងបែងចែកទៅតាមស្ថានភាពដែលមានមកដោយនារី "ខ" នឹងទទួលបានទ្រព្យច្រើនជាងលោក "ក" អាស្រ័យទៅលើការថែទាំ និងបង្កើនទ្រព្យសម្បត្តិ។

ដូចនេះហើយ សហព័ទ្ធនីមួយៗមានសិទ្ធិក្នុងការជ្រើសរើសថាពួកគេចង់បែងចែកទ្រព្យសម្បត្តិរបៀបណាដោយមានសេចក្តីសម្រេចពីតុលាការក្នុងការបែងចែកទ្រព្យសម្បត្តិសហព័ទ្ធ ហើយតុលាការត្រូវត្រួតពិនិត្យស្ថានភាពរបស់សហព័ទ្ធមុនធ្វើការបែងចែកដោយផ្អែកទៅលើកត្តាដែលបានរៀបរាប់ខាងលើនេះជាមុនសិន។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សានូវប្រព័ន្ធទ្រព្យសម្បត្តិរវាងសហព័ទ្ធហើយ យើងអាចសម្គាល់បានថាប្រព័ន្ធទ្រព្យសម្បត្តិកើតឡើងនៅពេលណា សហព័ទ្ធអាចសម្រេច ឬបែងចែកទ្រព្យសម្បត្តិដោយរបៀបណា និងតាមវិធីណាខ្លះដើម្បីមានភាពងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិ។ នៅពេលដែលសហព័ទ្ធបានយល់ដឹងច្បាស់លាស់អំពីប្រព័ន្ធទ្រព្យសម្បត្តិ សហព័ទ្ធអាចជ្រើសរើសរវាងការគ្រប់គ្រងប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់ ឬ ការគ្រប់គ្រងប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា។ នៅក្នុងជីវិតអាពាហ៍ពិពាហ៍ ការគ្រោះថ្លោយគឺតែងតែមាន ហេតុនេះហើយសហព័ន្ធអាចធ្វើការជ្រើសរើសថាតើគួរគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួន និងបែងចែកយ៉ាងដូចម្តេច។

ដោយសង្កេតមើលទិដ្ឋភាពសង្គមជាក់ស្តែង ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជាពុំសូវមានការយល់ដឹងច្បាស់ពីការគ្រប់គ្រងប្រព័ន្ធទ្រព្យសម្បត្តិសហព័ទ្ធនោះទេ ជាហេតុធ្វើឲមានចម្ងល់ និងវិវាទជាច្រើនរាប់មិនអស់បានកើតឡើងជាញឹកញយក្នុងអាពាហ៍ពិពាហ៍ប្តីប្រពន្ធទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ នៅពេលដែលសហព័ទ្ធសម្រេចចិត្តរំលាយចំណងអាពាហ៍ពិពាហ៍។ ដោយសារតែបញ្ហាគឺជាបញ្ហាដែលកើតមានឡើងក្នុងចំណងអាពាហ៍ពិពាហ៍ជាច្រើនទើបរាជរដ្ឋាភិបានលយកចិត្តទុកដាក់ និងធ្វើការបង្កើតច្បាប់នៃការគ្រប់គ្រងទ្រព្យសម្បត្តិសហព័ទ្ធនេះដើម្បីការពារសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិដាច់ដោយឡែករបស់សហព័ទ្ធពីការកេងប្រវ័ញ្ច នៅពេលសហព័ទ្ធមានករណីរំលាយអាពាហ៍ពិពាហ៍។ មានហេតុការណ៍ជាច្រើនករណីដែលតុលាការត្រូវធ្វើការវែកញែកទាក់ទងនឹងការរំលាយអាពាហ៍ពិពាហ៍រវាងសហព័ន្ធ និងបែងចែកទ្រព្យរួម និងទ្រព្យដាច់ដោយឡែកឲបានត្រឹមត្រូវ។

ច្បាប់កម្ពុជាមានប្រព័ន្ធច្បាស់លាស់សម្រាប់ការចុះឈ្មោះអាពាហ៍ពិពាហ៍ និងប្រព័ន្ធច្បាប់ត្រឹមត្រូវសម្រាប់ទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ ប៉ុន្តែច្បាប់មិនមែនមានភាពល្អគ្មានចន្លោះនោះទេ ភាពស្រពិចស្រពិលខ្លះនៅក្នុងច្បាប់ទាក់ទងនឹងការយល់ព្រមពីប្តី ឬ ប្រពន្ធក្នុងការបញ្ឈប់ទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍រួមហើយដែលជាបន្ទុកនៃការចំណាយគ្រួសារព្រោះការរំលាយអាពាហ៍ពិពាហ៍តែងតែមានផលលំបាកដល់សហព័ទ្ធ ដែលភាគច្រើនជាប្រពន្ធព្រោះស្ត្រីភាគច្រើនជាពិសេសស្ត្រីដែលនៅជនបទពឹងផ្អែកទៅលើប្តីដោយសារខ្លួនគ្មានការងារ ដែលនាំចំណូលបានប្រចាំខែសម្រាប់ចិញ្ចឹមជីវិតនោះទេ។ ហេតុនេះហើយ តុលាការគួរតែបញ្ជាក់ពីភាពមិនច្បាស់លាស់ទាំងនេះតាមរយៈការបង្កើតច្បាប់សំណុំរឿង និងធ្វើឱ្យវាអាចដំណើរការបានជាសាធារណៈដើម្បីឲប្រជាពលរដ្ឋយល់ដឹង។

យ៉ាងណាមិញ ទោះបីជារាជរដ្ឋាភិបាលបានរៀបរៀងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិសហព័ទ្ធក្តីភាពចន្លោះគ្លោះធ្លោយមិនមែនល្អឥតខ្ចោះ ប៉ុន្តែក៏នៅតែនៅតែមានកែប្រែផ្លាស់ប្តូរ។ ដូចដែលយើងបានបកស្រាយមកខាងលើ ប្រជាជនខ្មែរមិនសូវមានការយល់ដឹងច្បាស់លាស់អំពីច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិសហព័ទ្ធ

ដូច្នេះដើម្បីជៀសវាងវិវាទរវាងសហព័ទ្ធក្នុងការបែងចែកទ្រព្យសម្បត្តិ រាជរដ្ឋាភិបាលគួរមានវិធានការផ្សព្វផ្សាយទាក់ទងនឹងបញ្ហាមួយនេះដើម្បីបង្កើនការយល់ដឹងដល់បុគ្គលគ្រប់រូប។ គ្រប់បញ្ហាតែងតែមានដំណោះស្រាយ ហេតុនេះហើយ ច្បាប់ទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិរវាងសហព័ន្ធនេះនៅតែមានភាពផ្លាស់ប្តូរ និងកែតម្រូវទៅតាមសង្គមរស់នៅ។

# អនុសាសន៍

ច្បាប់នៅក្នុងប្រទេសនីមួយៗមិនមានភាពដូចគ្នាទាំងស្រុងនោះទេ ភាពខុសគ្នា និងការអនុវត្តិច្បាប់មានលក្ខណៈខុសផ្លែកពីគ្នាដោយរាប់ចូលច្បាប់ប្តីប្រពន្ធក៏ដូចគ្នាផងដែរ។ ក្នុងនាមស្វាមីនិងភរិយាការរស់នៅក្នុងផ្ទះតែមួយគឺជារឿងធម្មតាក្នុងជីវិតអាពាហ៍ពិពាហ៍។ ថ្វីបើមនុស្សជាច្រើនគិតថាអាពាហ៍ពិពាហ៍គឺជារឿងដ៏ស្រស់ស្អាតសម្រាប់មនុស្សនៅពេលពួកគេឈានដល់ដំណាក់កាលជាក់លាក់មួយ ដែលវាមានសារៈសំខាន់ណាស់ក្នុងការរៀបការ ឬ នៅពេលដែលពួកគេជួបស្នេហាក្នុងជីវិតរបស់ពួកគេប៉ុន្តែនេះមិនមានន័យថាអាពាហ៍ពិពាហ៍នឹងស្ថិតស្ថេរជារៀងរហូតនោះទេ។ នៅពេលមនុស្សពីរនាក់រៀបការមានរឿងជាច្រើនដែលពួកគេត្រូវធ្វើដើម្បីធានាភាពឯកជនជាពិសេសទ្រព្យសម្បត្តិ។ មនុស្សខ្លះមិនខ្វល់អំពីការចែករំលែកទ្រព្យសម្បត្តិជាមួយប្តី ឬ ប្រពន្ធ ឬ មិនខ្វល់អំពីការមិនបញ្ជាក់អំពីការញែកទ្រព្យសម្បត្តិរបស់ពួកគេបន្ទាប់ពីពួកគេលែងលះគ្នា ប៉ុន្តែមនុស្សខ្លះគិតពីទ្រព្យសម្បត្តិរបស់ពួកគេនៅពេលពួកគេរកបានដោយខ្លួនឯង ដែលជាមូលហេតុដែលប្រព័ន្ធទ្រព្យសម្បត្តិត្រូវបានបង្កើតឡើង។ ដូចដែល យើងបានដឹងហើយថាទោះបីជាច្បាប់ត្រូវបានបង្កើតឡើងដើម្បីការពារសិទ្ធិរបស់មនុស្ស ហើយច្បាប់នេះក៏មានចែងនៅក្នុងច្បាប់ទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ផងដែរ។ អាពាហ៍ពិពាហ៍គឺជាផ្នែកតូចមួយនៃជីវិតរបស់យើងហើយ នៅពេលដែលអ្នករៀបការអ្វីៗនឹងមិនដូចពេលអ្នកនៅលីវទេប៉ុន្តែនេះមិនមានន័យថាប្តី ឬ ប្រពន្ធទទួលបាននូវអ្វីគ្រប់យ៉ាងដែលយើងមាននោះទេ។

ច្បាប់ស្តីពីទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើង ដើម្បីការពារសិទ្ធិបុគ្គលចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ពួកគេមុនពេលរៀបការនិងក្រោយអាពាហ៍ពិពាហ៍ទាក់ទងនឹងទ្រព្យសម្បត្តិរួម។ ទោះបីជាច្បាប់នេះមានក៏ដោយ ក៏មិនមែនមានន័យថាវាល្អឥតខ្ចោះដែរប៉ុន្តែវានៅតែត្រូវការការកែលម្អនៅពេលដែលសង្គម និងប្រទេសវិវឌ្ឍ និងអភិវឌ្ឍន៍ជារៀងរាល់ថ្ងៃ។ យើងទាំងអស់គ្នាគឺជាមនុស្សផ្សេងគ្នាដែលមានជីវិត និងបរិយាកាសរស់នៅនិងស្ថានភាពគ្រួសារខុសពីគ្នា ដូច្នេះការលែងលះ និងបញ្ហាជាច្រើនទៀតបានកើតឡើងជារៀងរាល់ថ្ងៃ ហើយគ្មានអ្វីដែលជាចម្ងល់ឡើយដែលច្បាប់នេះបានផ្តល់យុត្តិធម៌ដល់ភាគីនីមួយៗ។ យោងតាមច្បាប់ប្រទេសកម្ពុជាបានចែងយ៉ាងច្បាស់អំពីបញ្ហាទាំងអស់ទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធ បន្ទាប់ពីពួកគេលែងលះគ្នា ឬក្នុងកាលៈទេសៈផ្សេងទៀតដែលអាចនាំឱ្យមានការបែងចែកទ្រព្យសម្បត្តិ។

បញ្ហាទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ គឺជាបញ្ហាចម្បងមួយនៅក្នុងជីវិតអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា។ តាមទស្សនៈរបស់ខ្ញុំខ្ញុំអាចមើលឃើញថាមនុស្សជាច្រើនមិនសូវមានចំណេះដឹងអំពីប្រព័ន្ធទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជាទេ ព្រោះស្ត្រីភាគច្រើននៅទីនេះជាស្ត្រីមេផ្ទះហើយអាចរស់បាន

តាមរយៈប្រាក់ខែប្តីរបស់ពួកគេ។ នៅប្រទេសកម្ពុជាមិនត្រឹមតែស្ត្រីមិនមានចំណេះដឹងតិចតួចអំពីទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ទេប៉ុន្តែចំពោះបុរសក៏ដូចគ្នាផងដែរ។ ប្រជាជនមិនបានទទួលការអប់រំគ្រប់គ្រាន់ទាក់ទងនឹងបញ្ហានេះដែលជាមូលហេតុដែលបញ្ហានេះហាក់ដូចជាមិនទៅដល់មនុស្សគ្រប់គ្នា។ មនុស្សគួរតែដឹងនិងដឹងនេះជាចំណេះដឹងទូទៅហើយវាក៏គួរត្រូវបានបង្រៀននៅក្នុងសាលាផងដែរ។ តាមសំណូមពររបស់ខ្ញុំ ខ្ញុំគិតថាជនជាតិខ្មែរគួរតែកែប្រែនូវនូវប្រព័ន្ធកម្មវិធីសិក្សារបស់សាលា ព្រោះមានចំណេះដឹងទូទៅជាច្រើនដែលសិស្សានុសិស្សមិនត្រូវបានរៀននៅសាលា។

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ, ១៧ ខែកក្កដា ឆ្នាំ១៩៨៩

## សៀវភៅ

ក្រសួងការងារយុត្តិធម៌. *ប្រកាសស្តីពីនីតិវិធីការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ*

## ដកស្រង់ចេញពីគេហទំព័រ៖

https://digitalcommons.law.lsu.edu/cgi/viewcontent.cgi?article=3293&context=lalrev

https://www.britannica.com/topic/community-property

https://www.construction-property.com/why-should-coupe-register-a-marital-property-agreement/

# ឧបសម្ព័ន្ធ

# គំរូពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឈ្មោះ............................................ភេទ ប្រុស អាយុ...........ថ្ងៃ ខែ ឆ្នាំកំណើត........................ជាប្តី ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ..............ផ្លូវលេខ..........ភូមិ...................................ឃុំ សង្កាត់...............................ក្រុង ស្រុក ខណ្ឌ................................រាជធានី ខេត្ត.......................................។

ឈ្មោះ............................................ភេទ ស្រី អាយុ............ថ្ងៃ ខែ ឆ្នាំកំណើត.......................................ជាប្រពន្ធ ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ ..........ភូមិ..........................ឃុំ សង្កាត់..........................ក្រុង ស្រុក ខណ្ឌ...........................រាជធានី ខេត្ត.......................................។

ឈ្មោះរបស់អ្នកតំណាង..................................................ភេទ.............អាយុ.............ថ្ងៃ ខែ ឆ្នាំកំណើត..................................អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...............ផ្លូវលេខ................ភូមិ..............................ឃុំ សង្កាត់......................ក្រុង ស្រុក ខណ្ឌ.....................រាជធានី ខេត្ត.......................................។

**សូមគោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កម្មវត្ថុ ៖** សំណើសុំចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជី : ..............................................................................................។
- មូលហេតុ : ..............................................................................................................។
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ : ...............................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

...................................................................................................................................។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើដោយក្តីអនុគ្រោះ។

ថ្ងៃ.....................................ខែ.............ឆ្នាំ.....................ព.ស...............

ធ្វើនៅ............................ថ្ងៃទី.........ខែ...........ឆ្នាំ...........

**ស្នាមម្រាមដៃ**

**ប្តីឈ្មោះ** **ប្រពន្ធឈ្មោះ**

## ឯកសារភ្ជាប់

## ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-សំបុត្រអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍

-វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ ) ក្នុងករណីដែលកិច្ចសន្យានេះពាក់ព័ន្ធនិងបញ្ហាដីធ្លី

-លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)

-អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

# គំរូពាក្យសុំចុះបញ្ជីអំពីការកែតម្រូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឈ្មោះ.......................................ភេទ ប្រុស អាយុ...........ថ្ងៃ ខែ ឆ្នាំកំណើត.........................ជាប្តី ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ.............ផ្លូវលេខ........ ភូមិ.................................ឃុំ សង្កាត់..............................ក្រុង ស្រុក ខណ្ឌ...............................រាជធានី ខេត្ត.....................................។

ឈ្មោះ.........................................ភេទ ស្រី អាយុ.........ថ្ងៃ ខែ ឆ្នាំកំណើត..................................... ជាប្រពន្ធ ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ.............. ផ្លូវលេខ.............ភូមិ...........................ឃុំ សង្កាត់.២......................ក្រុង ស្រុក ខណ្ឌ.២....................... រាជធានី ខេត្ត.....................................។

ឈ្មោះរបស់អ្នកតំណាង ........................................ភេទ...........អាយុ.............ថ្ងៃ ខែ ឆ្នាំកំណើត ..................................អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ផ្លូវលេខ...............ភូមិ.............................. ឃុំ សង្កាត់.....................ក្រុង ស្រុក ខណ្ឌ.៥................រាជធានី ខេត្ត.ស.................................។

**សូមគោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កម្មវត្ថុ ៖** សំណើសុំចុះបញ្ជីអំពីការកែតម្រូវការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជី : ...........................................................................................។
- មូលហេតុ : .......................................................................................................................។
- ចំណុចដែលត្រូវកែតម្រូវ:
  - ឈ្មោះ.......................................................................................................................
  - អាសយដ្ឋាន................................................................................................................

    .....................................................................................................................................
  - ថ្ងៃ ខែ ឆ្នាំកំណើត.......................................................................................................

- ខ្លឹមសារនៃទ្រព្យសម្បត្តិប្តីប្រពន្ធ.......................................................................................

.................................................................................................................................

.................................................................................................................................

.................................................................................................................................

.................................................................................................................................

.................................................................................................................................

.................................................................................................................................។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ថ្ងៃ.................................ខែ............ឆ្នាំ...................ព.ស.............

ធ្វើនៅ...........................ថ្ងៃទី.........ខែ...........ឆ្នាំ...........

**ស្នាមម្រាមដៃ**

**ប្តីឈ្មោះ** **ប្រពន្ធឈ្មោះ**

# ឯកសារភ្ជាប់

## ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-សំបុត្រអាពាហ៍ពិពាហ៍

-វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ ) ក្នុងករណីដែលកិច្ចសន្យានេះ ពាក់ព័ន្ធនិងបញ្ជាដីធ្លីក្រោយពេលមានការកែតម្រូវ

-លិខិតបញ្ជាក់អាសយដ្ឋាន

-លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)

-អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

# គំរូពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឈ្មោះ..................................ភេទ ប្រុស អាយុ..........ថ្ងៃ ខែ ឆ្នាំកំណើត..........................ជាប្តី☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............ផ្លូវលេខ........... ភូមិ................................ឃុំ សង្កាត់...............................ក្រុង ស្រុក ខណ្ឌ..............................រាជធានី ខេត្ត....................................។

ឈ្មោះ.........................................ភេទ ស្រី អាយុ.........ថ្ងៃ ខែ ឆ្នាំកំណើត.................................... ជាប្រពន្ធ ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............

ផ្លូវលេខ..............ភូមិ............................ឃុំ សង្កាត់..........................ក្រុង ស្រុក ខណ្ឌ.......................... រាជធានីខេត្ត....................................។

ឈ្មោះរបស់អ្នកតំណាង ............................................ភេទ...........អាយុ................ថ្ងៃ ខែ ឆ្នាំកំណើត ..................................អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ..............ផ្លូវលេខ................ភូមិ............................ ឃុំ សង្កាត់.......................ក្រុង ស្រុក ខណ្ឌ......................រាជធានី ខេត្ត.....................................។

**សូមគោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កម្មវត្ថុ ៖** សំណើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជី : ......................................................................................................។

- មូលហេតុ : ......................................................................................................................។

- ចំណុចដែលត្រូវផ្លាស់ប្តូរ : ........................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ថ្ងៃ.................................ខែ............ឆ្នាំ....................ព.ស..............

ធ្វើនៅ...........................ថ្ងៃទី.........ខែ...........ឆ្នាំ...........

**ស្នាមម្រាមដៃ**

**ប្តីឈ្មោះ** **ប្រពន្ធឈ្មោះ**

## ឯកសារភ្ជាប់

## ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

-កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធថ្មី

-សាលក្រម ឬ ដីកាសម្រេចផ្លាស់ប្ដូរ

-លិខិតបញ្ជាក់អំពីការផ្លាស់ប្ដូរអាសយដ្ឋាន

-វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ ) ក្នុងករណីដែលកិច្ចសន្យានេះ ពាក់ព័ន្ធនិងបញ្ហាដីធ្លីក្រោយពេលមានការផ្លាស់ប្ដូរ

-លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)

-អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

# គំរូពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរឈ្មោះ ឬ អាសយដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរឈ្មោះ ឬ អាសយដ្ឋាន**

ឈ្មោះ.....................................ភេទ ....... អាយុ...........ថ្ងៃ ខែ ឆ្នាំកំណើត..........................ជាប្ដី ☐ ឬប្រពន្ធ ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ.............

ផ្លូវលេខ..............ភូមិ.........................ឃុំ សង្កាត់...............................ក្រុង ស្រុក ខណ្ឌ..............................
រាជធានី ខេត្ត.......................................។

ឈ្មោះរបស់អ្នកតំណាង ...........................................ភេទ..............អាយុ................ថ្ងៃ ខែ ឆ្នាំកំណើត
..............................អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ.................ផ្លូវលេខ................ភូមិ..............................
ឃុំ សង្កាត់......................ក្រុង ស្រុក ខណ្ឌ....................រាជធានី ខេត្ត.......................................។

**សូមគោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កម្មវត្ថុ ៖** សំណើសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរឈ្មោះ ឬ អាសយដ្ឋាន។

- គោលបំណងនៃការចុះបញ្ជី : ..............................................................................................។

- មូលហេតុ : ...........................................................................................................................។

- ចំណុចដែលត្រូវផ្លាស់ប្ដូរ : ......................................................................................................

...................................................................................................................................................

...................................................................................................................................................។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្ដីអនុគ្រោះ។

ថ្ងៃ....................................ខែ............ឆ្នាំ....................ព.ស.............

ធ្វើនៅ............................ថ្ងៃទី.........ខែ...........ឆ្នាំ...........

**ស្នាមម្រាមដៃ**

**ឈ្មោះ**

# គំរូពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

ឈ្មោះ.......................................ភេទ ប្រុស អាយុ............ថ្ងៃ ខែ ឆ្នាំកំណើត...........................ជាប្តី ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............ផ្លូវលេខ............ ភូមិ...................................ឃុំ សង្កាត់.................................ក្រុង ស្រុក ខណ្ឌ...............................រាជធានី ខេត្ត......................................។

ឈ្មោះ...........................................ភេទ ស្រី អាយុ.........ថ្ងៃ ខែ ឆ្នាំកំណើត....................................... ជាប្រពន្ធ ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............

ផ្លូវលេខ................ភូមិ.............................ឃុំ សង្កាត់............................ក្រុង ស្រុក ខណ្ឌ........................... រាជធានី ខេត្ត.......................................។

ឈ្មោះរបស់អ្នកតំណាង .............................................ភេទ..............អាយុ................ថ្ងៃ ខែ ឆ្នាំកំណើត ...................................អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...............ផ្លូវលេខ................ភូមិ............................. ឃុំ សង្កាត់.......................ក្រុង ស្រុក ខណ្ឌ....................រាជធានី ខេត្ត.....................................។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កម្មវត្ថុ ៖** សំណើសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍។

- គោលបំណងនៃការចុះបញ្ជី ៖ ...................................................................................................។

- មូលហេតុ : ..........................................................................................................................។

- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ៖ .................................................................................។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ថ្ងៃ.......................................ខែ.............ឆ្នាំ.....................ព.ស..............

ធ្វើនៅ............................ថ្ងៃទី..........ខែ...........ឆ្នាំ...........

**ស្នាមម្រាមដៃ**

**ប្តីឈ្មោះ** **ប្រពន្ធឈ្មោះ**

## ឯកសារភ្ជាប់

## ពាក្យសុំចុះបញ្ជីអំពីការលះបង់ច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

-សំបុត្រអាពាហ៍ពិពាហ៍

-លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)

-អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន